**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# បណ្ដឹងតវ៉ារបស់តតិយជន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះលោក **ហួយ វិច្ឆិកា**
លោក **នឹង រ៉ុង**

សាស្ត្រាចារ្យណែនាំ
លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ**នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បណ្តឹងតវ៉ារបស់តតិយជន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **ឃួយ វិច្ឆិកា**

លោក **ឆឹង វ៉ុង**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហួយ វិច្ឆិកា** និង **ធឹង រ៉ុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រុម$L_4C_3$ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពជូនពរ ព្រមទាំងសំដែងនូវកតញ្ញូតាធម៌ និងគុណូបការៈដ៏ធំធេងដ៏ជ្រាលជ្រៅបំផុតចំពោះ ៖

- លោកឪពុក អ្នកម្តាយ ជាអ្នកមានគុណរបស់យើងខ្ញុំ សូមគោរពសំដែងនូវអំណរគុណប្រកបដោយ ភាពកត្តញ្ញូតាធម៌ដល់លោកទាំងទ្វេ ដែលបានផ្តល់កំណើត ខិតខំបីបាច់ ថែរក្សាកូន ផ្គត់ផ្គង់ ការសិក្សា រហូតដល់ធំពេញវ័យ។

- ឯកឧត្តមសាកលវិទ្យាធិការ និងលោកសាកលវិទ្យាធិការរង ព្រមទាំងលោក លោកស្រី និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចគ្រប់រូបដែលតែងតែខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ដើម្បីបង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងគ្រប់បែបយ៉ាងដល់យើងខ្ញុំ។

- សាស្ត្រាចារ្យ **ទេព សុខ** ដែលជាសាស្ត្រាចារ្យដឹកនាំក្នុងការស្រាវជ្រាវ និងបានផ្តល់នូវទស្សនទានថ្មីជុំវិញកិច្ចការស្រាវជ្រាវជាហូរហែរ រហូតយើងខ្ញុំអាចសម្រេចបាននូវកិច្ចការនេះ។ លោក បានខិតខំ ឆ្លៀតយកនូវពេលវេលាដ៏មានតម្លៃមកធ្វើការពន្យល់ណែនាំ និង កែលម្អនូវរាល់កំហុសឆ្គងទាំងឡាយជាកត្តាសម្រាប់ជំរុញការសិក្សាស្រាវជ្រាវរហូតទទួលជោគជ័យជាស្ថាពរ។

យើងខ្ញុំសូមឧទ្ទិសនូវស្នាដៃនេះជូនដល់បុព្វការីជន បុព្វបុរស វីរជនស្នេហាជាតិយុទ្ធជន យុទ្ធនារី និងនិស្សិតបញ្ញាវន្តខ្មែរទាំងអស់ដែលបានពលីជីវិតដើម្បីបុព្វហេតុជាតិ។

យើងសូមគោរពជូនពរលោក លោកស្រី អ្នកនាងកញ្ញា និងមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនូវពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាក់ខានឡើយ ។

# អំណះអំណាង

យើងខ្ញុំឈ្មោះ **ហួយ វិច្ឆិកា** និង **ធឹង រ៉ុង** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៩ ជំនាញនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវស្តីពី "**បណ្តឹងតវ៉ារបស់តតិយជន**" ប្រាកដមែន។

យើងខ្ញុំសូមធានាអះអាងថា ស្នាដៃនេះ ពិតជាត្រូវបានរៀបចំចងក្រង សិក្សាស្រាវជ្រាវរបស់យើងខ្ញុំដោយផ្ទាល់ពិតប្រាកដមែន ដោយរួមទាំងចំណេះដឹង ដែលបានទទួលក្នុងរយៈពេលសិក្សានៅសាកលវិទ្យាល័យថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និង មតិយោបល់ណែនាំរបស់អស់លោក លោកស្រី ជាសាស្ត្រាចារ្យទាំងអស់កន្លងមក ។

បន្ថែមពីនេះ យើងខ្ញុំក៏សូមអះអាងផងដែរ ថាស្នាដៃសិក្សាស្រាវជ្រាវនេះមិនមានចម្លង និងយកចេញពីអ្នកសិក្សាដទៃ លើកលែងតែមានកំណត់ច្បាស់លាស់ក្នុងប្រភពឯកសារដែលមានចង្អុលបង្ហាញក្នុងអត្ថបទត្រង់ចំនុចនីមួយៗពិតប្រាកដ និងទទួលខុសត្រូវចំពោះមុខច្បាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ហត្ថលេខា

# អារម្ភកថា

ក្នុងសង្គមសេដ្ឋកិច្ចទីផ្សារ បុគ្គលឯកជនម្នាក់ៗជាសមាជិកសង្គម ចូលរួមក្នុងជីវភាពសេដ្ឋកិច្ច តាមរយៈការដោះដូរទំនិញ និងសេវា ដោយប្រើប្រាស់រូបិយវត្ថុជាចម្បង។ ការដោះដូរទំនិញ និងសេវាត្រូវធ្វើឡើងតាមរយកិច្ចសន្យា ឬ ការសន្យារវាងបុគ្គលម្នាក់ និងបុគ្គលម្នាក់ទៀត។ ករណីជាច្រើនបុគ្គលនានាប្រតិបត្តិតាមកិច្ចសន្យា គោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយអនុវត្តករណីកិច្ចរបស់ខ្លួនដោយសេចក្តីសុចរិត។ វាជាធម្មតាដែលប្រជាពលរដ្ឋនៅក្នុងប្រទេសនីតិរដ្ឋត្រូវតែគោរពច្បាប់។

ប៉ុន្តែក្នុងសង្គមមួយតែងតែមានទំនាស់ដើម្បីប្រយោជន៍បុគ្គល ឬ ក្រុមណាមួយ ដែលកើតឡើងដោយការគេចវេសមិនទទួលខុសត្រូវ ប្រតិបត្តិតាមកិច្ចសន្យា និងគោរពសិទ្ធិរបស់ភាគីម្ខាងទៀត ហើយក៏មានការប្តឹងតវ៉ា ដើម្បីទាមទារប្រយោជន៍ពីភាគីម្ខាងទៀត ។

អាស្រ័យហេតុដូចនេះ យើងខ្ញុំបានសិក្សាពីប្រធានបទមួយ គឺ **បណ្តឹងតវ៉ារបស់ឥតិយជន** ដើម្បីឈ្វេងយល់អំពីច្បាប់ក្នុងការការពារសិទ្ធិស្របច្បាប់របស់បុគ្គល តាមរយៈការដោះស្រាយវិវាទដោយបង្ខំ។

យើងខ្ញុំសូមធ្វើការអភ័យទោសរាល់កំហុសឆ្គងនានា និងគោរពជូនពរដល់អ្នកសិក្សាទាំងអស់ ជួបនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៩

# មាតិកា

**ទំព័រ**

**តារាង** ........ v

**បញ្ជីឧបសម្ព័ន្ធ** ........ vi

## សេចក្តីផ្តើម

១. **លំនាំដើម** ........ ១

២. **កំនត់បញ្ហា** ........ ២

៣. **គោលបំណងនៃការស្រាវជ្រាវ** ........ ៣

៤. **វិធីសាស្ត្រស្រាវជ្រាវ** ........ ៣

៥. **ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ៣

៦. **សារៈសំខាន់នៃការស្រាវជ្រាវ** ........ ៤

៧. **រចនាសម្ព័ន្ធស្រាវជ្រាវ** ........ ៤

## ជំពូកទី១ សញ្ញាណទូទៅនៃបណ្តឹងតវ៉ា

១.១. **បណ្តឹងតវ៉ាចំពោះការទាមទារ** ........ ៥

១.១.១. ពេលដែលអាចដាក់ពាក្យបណ្តឹងចំពោះការទាមទារ ........ ៦

១.១.២. សមត្ថកិច្ចចំពោះបណ្តឹងតវ៉ាចំពោះការទាមទារ ........ ៧

១.២. **ការតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត** ........ ៧

១.២.១. មូលហេតុនាំឲ្យមានការដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ........ ៨

១.២.២. ពេលដែលត្រូវដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត ........ ៨

១.២.៣. សមត្ថកិច្ច ........ ៩

១.២.៤. ពន្ធដាក់ពាក្យសុំ ........ ៩

១.២.៥. នីតិវិធីដើម្បីចេញដីកាសម្រេច ........ ៩

១.២.៦. ការផ្អាកការអនុវត្តដោយបង្ខំ ........ ៩

១.២.៧. ដីការសម្រេច ........ ៩

១.៣. **បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត** ........ ១០

១.៣.១. បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត និងពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ១១

១.៣.២. ពេលដែលអាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ........ ១១

១.៣.៣. សាលក្រម ........ ១៣

១.៤. **បណ្ដឹងជំទាស់ និងការតវ៉ាចំពោះការអនុវត្ត** ........ ១៤

១.៥. **ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក** ........ ១៤

១.៥.១. ផលប្រយោជន៍នៃការតវ៉ា ........ ១៦

១.៥.២. នីតិវិធីការតវ៉ា ........ ១៧

១.៦. **បណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក** ........ ១៧

១.៦.១. គោលបំណងនៃបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងបែងចែកចំណែក ........ ១៨

១.៦.២. សមត្ថកិច្ច ........ ១៩

១.៦.៣. សាលក្រម ........ ២០

## ជំពូកទី ២ លំហូរនីតិវិធីបណ្ដឹងតវ៉ារបស់តតិយជន

២.១. **គោលបំណងនៃបណ្ដឹងតវ៉ារបស់តតិយជន** ........ ២១

២.២. **វិសាលភាពនៃបណ្ដឹងតវ៉ារបស់តតិយជន** ........ ២១

២.៣. **មូលហេតុនៃការតវ៉ារបស់តតិយជន** ........ ២២

២.៣.១. បណ្ដឹងតវ៉ារបស់តតិយជនដោយផ្អែកលើការភាន់ច្រឡំ ........ ២៣

២.៣.២. ការការពារតតិយជន ........ ២៤

២.៣.៣. គំនិតបដិសេធការអនុវត្ត ........ ២៤

២.៣.៤. បណ្ដឹងតវ៉ារបស់តតិយជនដោយផ្អែកលើការឆបោក ........ ២៥

២.៣.៥. បណ្ដឹងតវ៉ារបស់តតិយជនដោយផ្អែកលើការរំលោភបំពានលើស្ថានភាព ........ ២៦

២.៤. **លក្ខណៈជាតាគី** ........ ២៦

២.៥. **ពេលដែលអាចដាក់បណ្ដឹងតវ៉ារបស់តតិយជន** ........ ២៧

២.៦. **នីតិវិធីនៃ** ......................................................................................................... ២៨

២.៦.១. សមត្ថកិច្ច.............................................................................................................. ២៨

២.៦.២. ការដាក់ពាក្យបណ្តឹង.................................................................................................. ២៩

២.៦.៣. ការផ្អាកការអនុវត្តដោយបង្ខំ ដោយបណ្តឹងតវ៉ារបស់តតិយជន............................ ២៩

២.៦.៤. សាលក្រម ឬ សាលដីកា ................................................................................... ៣០

២.៧. **ពន្ធដាក់ពាក្យបណ្តឹង** ................................................................................................. ៣០

២.៨. **ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ** .......................................................... ៣១

## ជំពូកទី ៣ ចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន

៣.១. **ការរៀបចំពាក្យបណ្តឹង** ................................................................................................ ៣៣

៣.១.១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ......................... ៣៣

៣.២. **សមត្ថកិច្ចសាលាជម្រះក្តី**.............................................................................................. ៣៤

៣.៣. **ពេលដាក់ពាក្យបណ្តឹង**................................................................................................ ៣៤

៣.៤. **ការរួមបញ្ចូលបណ្តឹង** ................................................................................................. ៣៤

៣.៥. **ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង**....................................................................................... ៣៥

៣.៦. **ការវិនិច្ឆ័យបណ្តឹងតវ៉ារបស់តតិយជន**............................................................................ ៣៥

៣.៧. **អង្គហេតុចម្បង** .......................................................................................................... ៣៥

៣.៨. **ហេតុនៃការតវ៉ា**........................................................................................................... ៣៦

៣.៨.១. កម្មសិទ្ធិ ................................................................................................................ ៣៦

៣.៨.២. សិទ្ធិកាន់កាប់ ......................................................................................................... ៣៦

៣.៨.៣. សិទ្ធិជួលអចិន្ត្រៃយ៍ និងសិទ្ធិផលុបភោគ ជាអាទិ៍ ....................................................... ៣៦

៣.៨.៤. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត.............................................. ៣៧

៣.៨.៥. សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិ...................................................................................... ៣៧

៣.៨.៦. សិទ្ធិឃាត់ទុក........................................................................................................ ៣៧

៣.៨.៧. ប្រាតិភោគដោយអនុប្បទាន ........ ៣៨
៣.៨.៨. ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់ ........ ៣៨
៣.៩. **អាជ្ញាអស់ជំនុំ** ........ ៣៨
៣.១០. **នីតិវិធីក្រោយចេញសាលក្រម** ........ ៣៨
៣.១១. **ការសះជា** ........ ៣៩
៣.១២. **ការផ្អាកការអនុវត្ត** ........ ៣៩
៣.១២.១. លំហូរនៃការផ្អាក ........ ៤០
៣.១២.២. ពាក្យសុំផ្អាកការអនុវត្ត ........ ៤០
៣.១២.៣. លក្ខខណ្ឌនៃការផ្អាកការអនុវត្ត ........ ៤១
៣.១២.៤. វិធីវិនិច្ឆ័យ ........ ៤១
៣.១២.៥. អំពីប្រាតិភោគ ........ ៤១
៣.១២.៦. ខ្លឹមសារនៃដីកាសម្រេច ........ ៤២
៣.១២.៧. ដីកាសម្រេចផ្អាកការអនុវត្តដោយង្ខំ ........ ៤២
៣.១២.៨. សេចក្តីសម្រេចបញ្ចប់ ........ ៤៣

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

១ **សេចក្តីសន្និដ្ឋាន** ........ ៤៤
២ **អនុសាសន៍** ........ ៤៤
**ឧបសម្ព័ន្ធ**
**ឯកសារយោង**

# បញ្ជីតារាង

**ទំព័រ**

**តារាង ១** : តារាងលំហូរនៃការផ្អាកការអនុវត្ត..........................................................................៤០

# បញ្ជីឧបសម្ព័ន្ធ

១ **ឧបសម្ព័ន្ធទី១** : ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- មាត្រា ៣៥៦ រូបមន្តអនុវត្តពិសេស
- មាត្រា ៧៨១ អត្ថន័យនៃឯកសិទ្ធិ
- មាត្រា ៨៤៣ អត្ថន័យនៃហីប៉ូតែក

២ **ឧបសម្ព័ន្ធទី២** : ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

- មាត្រា ១៨ ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជម្រះក្តី
- មាត្រា ៥១ បណ្តឹងដែលមានដើមចោទ និងចុងចម្លើយ ជាសហាចុងចម្លើយ
- មាត្រា ៦១ ពន្ធដាក់ពាក្យសុំ
- មាត្រា ១១៤ ភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់
- មាត្រា ២៥៩ ប្រភេទបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់
- មាត្រា ៣៥១ វិសាលភាពនៃអ្នកដែលអនុវត្តដោយបង្ខំ
- មាត្រា ៣៦៣ បណ្តឹងតវ៉ាចំពោះការទាមទារ
- មាត្រា ៣៦៤ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត
- មាត្រា ៣៦៥ បណ្តឹងតវ៉ារបស់តតិយជន
- មាត្រា ៣៦៧ ការសម្រេចសេចក្តីផ្អាកអនុវត្តដោយការដាក់ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មីជាអាទិ៍
- មាត្រា ៣៧០ ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ

៣ **ឧបសម្ព័ន្ធទី៣** : សៀវភៅពន្យល់អំពី បណ្តឹង ការតវ៉ា និងបណ្តឹងជំទាស់ ទាក់ទងនឹងការអនុវត្ត

- បណ្តឹងតវ៉ារបស់តតិយជន

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំដើម

ក្នុងបរិបទឯកជនសាកលភាវូបនីកម្ម ធ្វើឲ្យការវិនិយោគមានភាពផុសផុលឡើងជាលំដាប់។ បុគ្គលឯកជនបានបង្កើតនូវទំនាក់ទំនងគតិយុត្តស្មុកស្មាញជាច្រើនដើម្បីដោះដូរ និងបំពេញទៅតាមតម្រូវការរៀងៗខ្លួន ដែលសកម្មភាពនេះបានបង្កឲ្យសភាពការណ៍ក្នុងប្រទេសពីមួយឆ្នាំទៅមួយឆ្នាំមានការវិវត្តយ៉ាងឆាប់រហ័ស។ ទន្ទឹមនេះបញ្ហាជាច្រើនអាចនឹងកើតមានឡើងជាយថាហេតុដែលបណ្តាលឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋស្លូតត្រង់ ដោយកើតពីការកិបកេងចំណេញ ឬ ការមិនព្រមអនុវត្តនូវកាតព្វកិច្ចដែលខ្លួនបានបង្កើត។

ដើម្បីធានាដល់ការធ្វើជំនួញ ជាពិសេសទំនាក់ទំនងក្នុងវិស័យពាណិជ្ជកម្មរវាងបុគ្គល ឯកជននោះ ការបង្កើតនូវលិខិតយថាភូតពីការព្រមព្រៀងរបស់ភាគីទាំងសងខាង គឺជាការចាំបាច់។

កិច្ចសន្យាត្រូវចាត់ទុកថាមានសុពលភាព អាចយកទៅអនុវត្តបានលុះត្រាតែកិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀង គ្នារវាងគូភាគីនៃកិច្ចសន្យានោះ។ ហើយដែលជាទូទៅកិច្ចសន្យានោះត្រូវមានកម្មវត្ថុស្របច្បាប់ និងត្រូវធ្វើឡើងដោយភាគីមានសមត្ថភាពក្នុងការចុះកិច្ចសន្យា។ នៅក្នុងករណីខ្លះ ទោះបីកិច្ចសន្យានោះត្រូវធ្វើ ដោយស្របទៅនឹងគោលគំនិតខាងលើក៏ដោយក៏វាអាចនឹងត្រូវបានលុបចោលបានផងដែរ ប្រសិនបើការបង្កើតកិច្ចសន្យានោះមានវិការៈ (វិការៈនៃការព្រមព្រៀង) រួមមានដូចជា កិច្ចសន្យានោះកើតឡើងដោយមានការភាន់ច្រឡំ (មាត្រា ៣៤៦) ការឆបោក (មាត្រា៣៤៧) ព័ត៌មានមិនពិត (មាត្រា៣៤៨) ការរំលោភបំពានលើស្ថានភាព (មាត្រា៣៤៩) ការគម្រាមកំហែង (មាត្រា ៣៥០) និងអំពើកេងយកចំណេញហួសហេតុ (មាត្រា៣៥១) ជាដើម។

បណ្តឹងតវ៉ារបស់តតិយជន វាគឺជាភាពចាំបាច់ក្នុងគោល បំណងដើម្បីការពារផលប្រយោជន៍របស់តតិយជន ជាពិសេសដើម្បីកុំឱ្យផលប៉ះពាល់សុវត្ថិភាពក្នុងកិច្ចការជំនួញ និងសណ្តាប់ធ្នាប់សង្គមដែលកើតឡើងដោយសារការង្កើត កិច្ចសន្យាដោយមានវិការៈ។ ដូច្នោះហើយ មធ្យោបាយសមស្របទាំងឡាយដើម្បីការពារតតិយជន គឺជាការចាំបាច់បំផុត។

ដោយសារចរិកលក្ខណៈពីធម្មជាតិរបស់មនុស្សនេះហើយ បានបង្កឲ្យទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនមិនមានសមភាពព្រោះថា ភាពអាត្មានិយម និងការខ្វែងគំនិតគ្នាខាងផ្នែកផលប្រយោជន៍បានបង្កើតនូវទំនាស់រវាងបុគ្គលដែលមានឋានៈការងារ ឬឋទពិសោធន៍ខ្ពស់ជាងបុគ្គលម្នាក់ទៀត។

ដើម្បីឆ្លើយតបទៅនឹងភាពរីកចំរើនឥតឈប់ឈរ ជាមួយនឹងការប្រែប្រួលស្ថានភាពសង្គមនយោបាយ រដ្ឋបានបង្កើតឲ្យមាននូវទំនើបកម្មគតិយុត្តឲ្យស្របទៅតាមស្ថានភាពជាក់ស្តែងរបស់សង្គមក្នុងគោលបំណង ដើម្បីគ្រប់គ្រងទៅលើបណ្តាសកម្មភាពទាំងអស់របស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានារក្សាបាននូវសណ្តាប់ធ្នាប់សារធារណៈ និងរបៀបរៀបរយសង្គម ពីព្រោះការបង្កើតទំនាក់ទំនងគតិយុត្តក្នុងសកម្មភាពវិនិយោគ អាចបង្កើតឲ្យមានការខ្វែងគំនិតគ្នាខាងផ្នែកផលប្រយោជន៍ដែលអាចនាំឲ្យកើតមានជម្លោះ។

រាល់បញ្ហាផ្សេងៗអាចនឹងកើតមានជាយថាហេតុនោះ ទើបជម្រុញឲ្យកិច្ចសហប្រតិបត្តការរវាងក្រសួងយុត្តិធម៌ និងទីភ្នាក់ងារសហប្រតិបត្តការអន្តរជាតិនៃប្រទេសជប៉ុន បានបង្កើតឲ្យមានក្រមនីតិវិធីរដ្ឋប្បវេណីនៅឆ្នាំ២០០៦។ ក្រមនីតិវិធីរដ្ឋប្បវេណីនេះ បានបង្ហាញនូវសញ្ញាណនៃបណ្តឹងតវ៉ារបស់តតិយជន ដែលមានការខុសប្លែកពីការអនុវត្តនូវបណ្តឹងតវ៉ាផ្សេងៗទៀត ហើយត្រូវបានលើកយកមកពិភាក្សាជាប្រធានបទសារណានៅពេលនេះ។

## ២. កំនត់បញ្ហា

ការអនុវត្តដោយបង្ខំគ្រប់ប្រភេទ អាចនឹងបង្កឲ្យមានផលប៉ះពាល់មិនត្រឹមត្រូវដល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជន។ បណ្តឹងតវ៉ារបស់តតិយជនស្ថិតក្រោមនីតិវិធីនៃបណ្តឹងអង្គសេចក្តីធម្មតា។ ហេតុនេះវាត្រូវគោរពគោលការណ៍នៃមាត្រា ៧៤ ផលប្រយោជន៍នៃបណ្តឹង។ ប្រសិនបើបណ្តឹងតវ៉ារបស់តតិយជនត្រូវបានដាក់ក្រោយនីតិវិធិនៃការចែកចំណែក ឬក្រោយពេលបញ្ចប់នីតិវិធីអនុវត្តដោយបង្ខំ វាធ្វើអោយសាលក្រមដែលលុបចោលការអនុវត្តដោយបង្ខំក្លាយទៅជាគ្មានន័យ តែវាក៏មិនបិទសិទ្ធិដល់តតិយជន មិនឲ្យដាក់ពាក្យបណ្តឹងផ្អែកលើសេចក្តីចម្រើនដោយឥតហេតុបានដែរ។ ដើម្បីធ្វើការសិក្សាស្វែងយល់ឲ្យបានច្រើន យើងខ្ញុំបានលើកឡើងនូវបញ្ហាគតិយុត្តដូចខាងក្រោម៖

តើបណ្តឹងតវ៉ារបស់តតិយជនធ្វើឡើងដូចម្តេច? តើតតិយជនទទួលបានប្រយោជន៍យ៉ាងដូចម្តេចចំពោះបណ្តឹងនេះ?

តើគេមានចំណាត់ការដូចម្តេចចំពោះបណ្តឹងតវ៉ារបស់តតិយជន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសារតែការចាត់ចែងរបស់ស្ថាប័នអនុវត្តអាចនឹងបណ្ដាលឲ្យខូចខាតផលប្រយោជន៍មិនត្រឹមត្រូវរបស់តតិយជននៅក្នុងនីតិវិធិអនុវត្តដោយបង្ខំ វាជាមូលហេតុដែលនាំឲ្យតតិយជនទទួលបានសិទ្ធិធ្វើបណ្ដឹងតវ៉ាចំពោះការអនុវត្តដែលប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

ជាក់ស្ដែង ការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីសម្រេចគោលបំណងឈ្វេងយល់ពី សញ្ញាណនៃបណ្ដឹងតវ៉ា ពិសេសបណ្ដឹងតវ៉ារបស់តតិយជន ដែលកន្លងមកអាចនឹងមានផលប៉ះពាល់មិនត្រឹមត្រូវដល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជន ដោយសារការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ហេតុនេះតតិយជនគប្បីមានសិទ្ធិតវ៉ាចំពោះការអនុវត្តដោយបង្ខំនេះ។

## ៤. វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងវិធីសាស្ត្រស្រាវជ្រាវ គឺជាផ្នែកមួយដែលលើកមកធ្វើការសិក្សាទៅលើប្រធានបទដើម្បីប្រមូលនូវព័ត៌មានជាជំនួយដល់ការស្រាវជ្រាវប្រកបដោយលក្ខណៈត្រឹមត្រូវ ច្បាស់លាស់។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ និងដើម្បីប្រមូលពត៌មានឱ្យបានលម្អិតត្រឹមត្រូវ និងឱ្យរឹតតែស៊ីជម្រៅថែមទៅទៀតនោះ យើងខ្ញុំបានធ្វើការជ្រើសរើសការស្រាវជ្រាវទៅតាមបែបគុណវិស័យ គឺជាការស្រាវជ្រាវមួយដែលតម្រូវឱ្យយើងខ្ញុំធ្វើការប្រមូលពត៌មានលម្អិតជុំវិញប្រធានបទហើយធ្វើការប៉ាន់ស្មាន និងវាយតម្លៃរាល់លទ្ធផល រាល់ឯកសារទាំងឡាយបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវតាមរូបភាពផ្សេងៗ ដែលយើងខ្ញុំបានធ្វើការប្រមូលនោះយកមកធ្វើការវិភាគដើម្បីបានលទ្ធផលសម្រេចមួយ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះ យើងធ្វើឡើងក្នុងប្រទេសកម្ពុជា ដោយហេតុថាបណ្ដឹងតវ៉ាមានច្រើនផ្នែក ដូចនេះហើយយើងផ្ដោតសំខាន់ទៅលើ បណ្ដឹងតវ៉ារបស់តតិយជន និងចំណាត់ការរបស់បណ្ដឹងតវ៉ារបស់តតិយជន ដែលបានចាប់ផ្ដើមធ្វើការស្រាវជ្រាវនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩។ ជាងនេះទៅទៀតវង្វង់នៃការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងចំពោះមាត្រាដែលបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃឆ្នាំ២០០៦ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ តែប៉ុណ្ណោះ សម្រាប់សរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពេលការស្រាវជ្រាវនេះត្រូវបានបញ្ចប់ នឹងអាចផ្តល់អត្ថប្រយោជន៍មួយចំនួនសម្រាប់ការសិក្សាស្រាវជ្រាវពង្រីកនូវចំណេះដឹងបន្ថែម របស់ប្អូនៗ មិត្តនិស្សិត ក៏ដូចជាការចូលរួមជាវិភាគទាននៅក្នុងការចែករំលែកជូនទៅដល់បងប្អូនប្រជាពលរដ្ឋ នៅក្នុងការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធទៅនឹង បណ្តឹងតវ៉ារបស់តតិយជន។

## ៧. រចនាសម្ព័ន្ធស្រាវជ្រាវ

ដើម្បីធ្វើឱ្យការសិក្សាលើប្រធានកាន់តែល្អប្រសើរ និងច្បាស់លាស់ថែមទៀតនោះយើងខ្ញុំសូមធ្វើការបែងចែកជា ៣ជំពូកធំៗគឺៈ

- ជំពូកទី១ សញ្ញាណទូទៅនៃបណ្តឹងតវ៉ា
- ជំពូកទី២ លំហូរនីតិវិធីនៃបណ្តឹងតវ៉ារបស់តតិយជន
- ជំពូកទី៣ ចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន
- សេចក្តីសន្និដ្ឋាន

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងតវ៉ា

# ជំពូកទី១

# សញ្ញាណទូទៅនៃបណ្ដឹងតវ៉ា

## ១.១. បណ្ដឹងតវ៉ាចំពោះការទាមទារ

បណ្ដឹងតវ៉ា ជាបណ្ដឹងដែលប្ដឹងប្រឆាំងនឹងម្ចាស់បំណុលនៃការអនុវត្តដោយអះអាងថា កម្មវត្ថុនៃការអនុវត្ត មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវ ស្ថិតក្រោមច្បាប់ ដែលអាចធ្វើឲ្យខូចប្រយោជន៍ ហើយទាមទារឲ្យដកចេញនូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិទាំងនោះ។

កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត អាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការទាមទារ ដើម្បីឲ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន។[1]

ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តបានឡើយចំពោះ៖

- សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន។
- ដីការសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយនឹងការប្រកាសអនុវត្តជាបណ្ដោះអាសន្ន។

ការមិនកើតមាននូវសិទ្ធិទាមទារ មានដូចជា ការមិនបានបង្កើតនូវកិច្ចសន្យា ឬ កិច្ចសន្យាបង្កើតឡើងដោយការភាន់ច្រឡំ ការឆបោក ឬ ការគំរាមកំហែង។

ការរំលត់នៃសិទ្ធិទាមទារ ដោយលើកឡើងពីការបំពេញកាតព្វកិច្ច ការទូទាត់ ការលើកលែង ការបញ្ចប់កិច្ចសន្យា និងការផុតអាជ្ញាយុកាល គឺដើមចោទក៏អាចលើកឡើងអំពីការរំលត់នៃសិទ្ធិទាមទារ ដោយលើកឡើងពីការបំពេញកាតព្វកិច្ច ការទូទាត់ ការលើកលែង ការបញ្ចប់កិច្ចសន្យា ឬ ការផុតអាជ្ញាយុកាល ជាដើម។

ចំពោះការលើកមូលហេតុនេះ គឺដើមចោទអាចលើកបានក្នុងករណីដែលមូលហេតុទាំងនោះកើតឡើងក្រោយបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ក្នុងករណីលិខិតអនុវត្តគឺជាសាលក្រមចុងក្រោយ។ ករណីនេះ ហេតុដែលកើតមុនការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់គឺមិនអាចលើកឡើងបានទេ។

[1] មាត្រា ៣៦៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដើមចោទ និង ចុងចម្លើយ ក្នុងករណីបណ្តឹងតវ៉ាចំពោះការទាមទារ គឺកូនបំណុលនៃការអនុវត្តដដែលមានការតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារ ដែលបានកំណត់នៅក្នុងលិខិតអនុវត្តអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារដើម្បីកុំឲ្យតុលាការអនុញ្ញាតអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតនោះបាន។[2]

### ១.១.១. ពេលដែលអាចដាក់ពាក្យបណ្តឹងចំពោះការទាមទារ

ជាទូទៅចំពោះកូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារពេលណាក៏បាន សូម្បីមុនពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ ឲ្យតែមានមូលហេតុនៃការតវ៉ាចំពោះលិខិតអនុវត្តរហូតដល់មុនពេលការអនុវត្តត្រូវបានបញ្ចប់។

ករណីលើកលែង នៅក្នុងករណីដែលលិខិតអនុវត្ត គឺជាសាលក្រម ឬសាលដីកា បង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងនការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន បណ្តឹងតវ៉ាចំពោះការទាមទារ មិនអាចធ្វើបានឡើយ បើមិនទាន់ចូលជាស្ថាពរ។

មូលហេតុ គឺដោយសារវិធីដទៃផ្សេងទៀត ដើម្បីតវ៉ាចំពោះអនុភាពដែលកើតមានដូចជាបណ្តឹងឧបាស្រ័យ ឬ ការតវ៉ាចំពោះការចេញដីកាសម្រេចដាស់តឿន។

ករណីដែល បណ្តឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឲ្យតុលាការអនុញ្ញាតការអនុវត្ត ដោយបង្ខំដែលបានកំណត់ តាមរយៈបណ្តឹងតវ៉ា ចំពោះការទាមទារ មានតែជន ដែលបានកំណត់ថា កូនបំណុលនៅក្នុងរូបមន្តអនុវត្តតែប៉ុណ្ណោះ អាចដាក់ពាក្យបណ្តឹងពីពេលដែលម្ចាស់បំណុលដាក់ពាក្យសុំអនុវត្តដោយបង្ខំរហូតដល់មុនពេលការអនុវត្តត្រូវបានបញ្ចប់។

ករណីដែលការអនុវត្តដោយបង្ខំត្រូវបានបញ្ចប់ហើយ ប៉ុន្តែម្ចាស់បំណុលនៃការអនុវត្តមិនទាន់បានទទួលសំណងគ្រប់ចំនួនតាមទំហំបំណុល ក្នុងរូបមន្តអនុវត្ត ដោយសារតែកូនបំណុលមានទ្រព្យសម្បត្តិតែប៉ុណ្ណោះ កូនបំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារបាន ចាប់ពីពេលដែលមានមូលហេតុនៃការតវ៉ាចំពោះសាលក្រម ឬសាលដីកាស្ថាពរ។

[២] កថាខណ្ឌទី១ មាត្រា ៣៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

### ១.១.២.សមត្ថកិច្ចចំពោះបណ្តឹងតវ៉ាចំពោះការទាមទារ

សមត្ថកិច្ចរបស់តុលាការចំពោះបណ្តឹងតវ៉ាចំពោះការទាមទារ យោងតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗដូចខាងក្រោមនេះ៖

ក- ចំពោះលិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ក រហូតដល់ចំណុច ឃ ឬ ចាប់ពីចំណុច ឆ រហូតដល់ចំណុច ឈ កថាខណ្ឌទី២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺសាលាដំបូងនៃនីតិវិធីសម្រេចសេចក្តី។

ខ- ចំពោះលិខិតអនុវត្ត ដែលបានកំណត់ចាប់ពីចំណុច ង កថាខណ្ឌទី២ មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតុលាការដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះស្ថិតនៅ។

គ- ចំពោះលិខិតដែលបានកំណត់ចាប់ពីចំណុច ច កថាខណ្ឌទី២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយ ដែលកំណត់ដោយមាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ បើពុំមានតុលាការដែលមានសមត្ថកិច្ចតាមមាត្រានេះទេ តុលាការដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តដែលរឹបអូសបានស្ថិតនៅ។

## ១.២. ការតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត

ពេលដែលសាក្រមបានចូលជាស្ថាពរហើយ ម្ចាស់បំណុលនៃការអនុវត្តត្រូវការរូបមន្តអនុវត្តជាចាំបាច់ ដើម្បីយកទៅអនុវត្តដោយបង្ខំ (សាលក្រមដែលភ្ជាប់រូបមន្តអនុវត្ត) ហើយការចាត់ចែងផ្តល់រូបមន្តអនុវត្ត គឺជាភារកិច្ចរបស់ក្រឡាបញ្ជី បន្ទាប់ពីមានពាក្យសុំរបស់ម្ចាស់បំណុល ហើយចំពោះការចាត់ចែងនេះមានពីរគឺ៖

- ការផ្តល់រូបមន្តអនុវត្តទៅឲ្យម្ចាស់បំណុល
- ការមិនផ្តល់រូបមន្តអនុវត្តឲ្យទៅម្ចាស់បំណុល

ក្នុងការតវ៉ានេះ អ្នកដែលមានផលប្រយោជន៍ធ្វើការតវ៉ា ចំពោះការចាត់ចែងក្នុងការផ្តល់រូបមន្តអនុវត្តគឺ៖

- នៅពេលក្រឡាបញ្ជីបានផ្តល់រូបមន្តអនុវត្តទៅឲ្យម្ចាស់បំណុលតាមពាក្យសុំ ហើយអ្នកដែលមិនពេញចិត្តក្នុងការផ្តល់រូបមន្តនោះ គឺមានតែកូនបំណុលតែប៉ុណ្ណោះ។

- ពេលក្រឡាបញ្ជីមិនបានផ្តល់រូបមន្តអនុវត្តទៅឲ្យម្ចាស់បំណុល តាមពាក្យសុំរបស់ម្ចាស់បំណុលទេ អ្នកដែលមិនពេញចិត្តចំពោះការមិនផ្តល់រូបមន្តអនុវត្តនេះ គឺម្ចាស់បំណុល។

### **១.២.១.មូលហេតុនាំឲ្យមានការដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត**

ពុំមានចែងអំពីមូលហេតុទេ ប៉ុន្តែគ្រប់មូលហេតុទាំងអស់ ដែលគូភាគីយល់ថា ការចាត់ចែងចំពោះការផ្តល់រូបមន្តអនុវត្ត ឬ មិនផ្តល់រូបមន្តអនុវត្តរបស់ក្រឡាបញ្ជីធ្វើឡើងមិនត្រឹមត្រូវនោះគូភាគីអាចដាក់ពាក្យសុំតវ៉ាបាន។

តុលាការមានឆន្ទានុសិទ្ធិទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការផ្តល់រូបមន្តអនុវត្តរបស់ក្រឡាបញ្ជី ប៉ុន្តែការទទួលស្គាល់ ឬ មិនទទួលស្គាល់នេះ មិនមានអ្វីទាក់ទងទៅនឹងអនុភាពនៃលិខិតអនុវត្តទេ។ ប៉ុន្តែទោះបីជា ការចាត់ចែងរបស់ក្រឡាបញ្ជីស្របច្បាប់ក្តី ឬ ផ្ទុយច្បាប់ក្តី ម្ចាស់បំណុលអាចដាក់ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្តជាថ្មីម្តងទៀតបាន។

### **១.២.២. ពេលដែលត្រូវដាក់ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត**

ពុំមានចែងអំពីពេលវេលាដែលគូភាគីដាក់ពាក្យសុំតវ៉ាទេ គូភាគីអាចដាក់ពាក្យសុំតវ៉ាពេលណាក៏បានដែរ បន្ទាប់ពីក្រឡាបញ្ជីបានផ្តល់រូបមន្តអនុវត្ត ឬ មិនផ្តល់រូបមន្តអនុវត្ត។

#### **ក- ការផ្តល់រូបមន្តអនុវត្ត**

ករណីនេះ កូនបំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបន្តអនុវត្តនៅមុនពេល ឬ ក្រោយពេលចាប់ផ្តើមការអនុវត្តដោយបង្ខំ ប៉ុន្តែបើការអនុវត្តដោយបង្ខំ បានធ្វើចប់សព្វគ្រប់ហើយកូនបំណុលមិនអាចដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តបានទេ ព្រោះវាគ្មានផលប្រយោជន៍ទៀតទេចំពោះកូនបំណុល។

#### **ខ- ការមិនផ្តល់រូបមន្តអនុវត្ត**

បើសិនក្រឡាបញ្ជីមិនបានផ្តល់រូបមន្តអនុវត្តឲ្យម្ចាស់បំណុល នោះការអនុវត្តដោយបង្ខំមិនបានចាប់ផ្តើមទេ ដូចនេះមានន័យថា មិនមានការចាប់ផ្តើមការអនុវត្តដោយបង្ខំឡើយ ហើយម្ចាស់បំណុលអាចដាក់ពាក្យសុំតវ៉ាចំពោះការមិនផ្តល់រូបមន្តអនុវត្តនៅពេលណាក៏បានដែរ បន្ទាប់ពីមានការមិនផ្តល់រូបមន្តដែលត្រូវចាត់ចែងដោយក្រឡាបញ្ជី។

### **១.២.៣. សមត្ថកិច្ច**

បើការផ្តល់រូបមន្តអនុវត្ត ជាការចាត់ចែងរបស់ក្រឡាបញ្ជី អ្នកដាក់ពាក្យសុំតវ៉ា អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនៅ។

ប៉ុន្តែបើការចាត់ចែងរបស់សារការី អ្នកដាក់ពាក្យសុំតវ៉ាអាចដាក់ពាក្យសុំតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងនៃការិយាល័យរបស់សារការីនោះ។

### **១.២.៤. ពន្ធដាក់ពាក្យសុំ**

តាមប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពី ប្រភេទពាក្យសុំដែលតម្រូវឲ្យបង់ពន្ធ ចំនួនទឹកប្រាក់នៃពន្ធដាក់ពាក្យសុំ និងចំនួន ត្រូវបង់ដើម្បីធ្វើសកម្មភាពក្រៅពីពាក្យសុំទៅតុលាការឲ្យសម្រេចសេចក្តី និង មាត្រដ្ឋានសម្រាប់គណនាប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងតម្លៃកម្មវត្ថុនៃបណ្តឹង ពន្ធដាក់ពាក្យសុំ គឺត្រូវបង់ចំនួន ៥០០០រៀល។

### **១.២.៥. នីតិវិធីដើម្បីចេញដីកាសម្រេច**

ការសម្រេចសេចក្តីអំពីពាក្យសុំតវ៉ា គឺត្រូវធ្វើដោយដីកាសម្រេច។ ដើម្បីចេញដីកាសម្រេច តុលាការមិនចាំបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ ប៉ុន្តែបើយល់ថាចាំបាច់តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។[3]

### **១.២.៦. ការផ្អាកការអនុវត្តដោយបង្ខំ**

ពេលដាក់ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដាក់ពាក្យសុំតវ៉ា គឺមិនមែនមានន័យថាការអនុវត្តដោយបង្ខំត្រូវផ្អាកដោយស្វ័យប្រវត្តិនោះទេ។ ដូចនេះ អ្នកដាក់ពាក្យសុំតវ៉ានោះត្រូវដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំមួយទៀត ទៅតុលាការដែលទទួលពាក្យសុំតវ៉ានោះ។

បន្ទាប់ពីបានទទួលដីការសម្រេចឲ្យផ្អាកការអនុវត្តដោយបង្ខំហើយ អ្នកដាក់ពាក្យសុំតវ៉ាត្រូវដាក់ដីកាសម្រេចនោះទៅតុលាការអនុវត្ត ឬ អាជ្ញាសាលា ទៅតាមករណីនីមួយៗ។[4]

### **១.២.៧. ដីការសម្រេច**

#### **ក- ពាក្យសុំតវ៉ាចំពោះការបដិសេធមិនផ្តល់រូបមន្តអនុវត្ត**

[៣] មាត្រា ១១៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[៤] មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ឆ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ករណីដែលក្រឡាបញ្ជី ឬ សារការី មិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលដាក់ពាក្យសុំតវ៉ា។ ក្នុងករណីនោះ តុលាការត្រូវពិនិត្យទៅលើមូលហេតុនៃពាក្យសុំតវ៉ានោះ។

- ប្រសិនបើមានមូលហេតុត្រឹមត្រូវ តុលាការចេញដីកាសម្រេចនូវចំណុចខាងក្រោម៖
  - ➢ លុបចោលការមិនព្រមផ្តល់រូបមន្តអនុវត្ត
  - ➢ បង្គាប់ឲ្យផ្តល់រូបមន្តអនុវត្ត។

នៅពេលដែលទទួលបានដីការសម្រេចនេះហើយ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំផ្តល់រូបមន្តអនុវត្តជាថ្មីម្តងទៀត ដោយភ្ជាប់ជាមួយដីកាសម្រេច។

- ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវលុបចោលពាក្យសុំតវ៉ានោះ។

### ខ- ពាក្យសុំតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

ក្នុងករណីដែលក្រឡាបញ្ជី ឬ សារការី ផ្តល់រូបន្តអនុវត្ត កូនបំណុលដាក់ពាក្យសុំតវ៉ា។ ក្នុងករណីនោះ តុលាការត្រូវពិនិត្យទៅលើមូលហេតុនៃពាក្យសុំតវ៉ានោះ។

- បើមានមូលហេតុត្រឹមត្រូវ តុលាការចេញដីការសម្រេចដែលមានខ្លឹមសារដូចខាងក្រោម៖
  - ➢ លុបចោលការផ្តល់រូបមន្តអនុវត្ត
  - ➢ ការអនុវត្តដោយបង្ខំដោយផ្អែកលើសាលក្រមចុងក្រោយ
- ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចនឹងចេញដីកាសម្រេចលើកចោលពាក្យសុំតវ៉ានោះ។

## ១.៣. បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត គឺធ្វើឡើងដោយកូនបំណុលនៃការអនុវត្ត ទាមទារកុំឲ្យធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តពិសេស[5] ដោយអាចអះអាងអំពីនត្ថិភាពនៃហេតុដែលជាលក្ខខណ្ឌនៃការផ្តល់រូបមន្តអនុវត្តពិសេស ចំពោះលក្ខខណ្ឌបង្អង់ ចំពោះការមកដល់ពេលកំណត់មិនពិតប្រាកដ ឬ ចំពោះលទ្ធភាព

[5] មាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ដែលអាចធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត[6] ហើយយកម្ចាស់បំណុលនៃការអនុវត្តមកធ្វើជាចុងចម្លើយ។

### ១.៣.១. បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត និង ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត

ការតវ៉ាអាចធ្វើបាន ចំពោះរាល់ការចាត់ចែងរបស់ក្រឡាបញ្ជី ឬ សារការីពាក់ព័ន្ធនឹងការសុំឲ្យផ្ដល់រូបមន្តអនុវត្តដែលមានទាំងការផ្ដល់រូបមន្តអនុវត្ត និងការមិនផ្ដល់រូបមន្តអនុវត្ត។ ហេតុដូចនេះ គូភាគី គឺ ដើមចោទ និងចុងចម្លើយ អាចដាក់ពាក្យបណ្ដឹងតវ៉ាបានដូចគ្នា។

ដោយឡែក មានកំរិតលក្ខខណ្ឌក្នុងការធ្វើបណ្ដឹងបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត[7]។ ក្នុងករណីនេះ មានតែកូនបំណុលនៃការអនុវត្តប៉ុណ្ណោះដែលមានសិទ្ធិប្ដឹង ហើយអាចធ្វើបានក្នុងបីករណីដូចខាងក្រោមះ

- ពេលកំណត់មិនពិតប្រាកដ
- លក្ខខណ្ឌបង្អង់
- លទ្ធភាពដែលអាចធ្វើការអនុវត្តដោយបង្ខំលើបុគ្គលក្រៅពីភាគីក្នុងលិខិតអនុវត្ត

ដើមចោទក្នុងរឿងក្ដីនេះ គឺកូនបំណុលនៃការអនុវត្ត ឬ បុគ្គលក្រៅពីភាគីក្នុងលិខិតអនុវត្តដែលត្រូវទទួលរងនូវអានុភាពនៃការអនុវត្ត។ ចុងចម្លើយនៅក្នុងរឿងក្ដីនេះ គឺម្ចាស់បំណុលនៃការអនុវត្ត។

### ១.៣.២. ពេលដែលអាចដាក់ពាក្យបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត

កូនបំណុលនៃការអនុវត្ត អាចដាក់បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ចាប់តាំងពីពេលដែលមានការផ្ដល់រូបមន្តអនុវត្តរហូតដល់ពេលអនុវត្តដោយបង្ខំមិនទាន់ត្រូវបានបញ្ចប់។ ប្រសិនបើការអនុវត្តដោយបង្ខំបានធ្វើចប់សព្វគ្រប់ហើយនោះ កូនបំណុលនៃការអនុវត្តនឹងគ្មានផលប្រយោជន៍ក្នុងការដាក់ពាក្យបណ្ដឹងតវ៉ានោះទេ។

[៦] មាត្រា ៣៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[៧] មាត្រា ៣៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការតាមការកំណត់នីមួយៗ ដោយយោងទៅតាមផ្នែកនៃលិខិតអនុវត្តដែលបានកំណត់ក្នុងចំណុចនីមួយៗដូចខាងក្រោមនេះ៖

- លិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ក រហូតដល់ចំណុច ឃ ឬ ចាប់ពីចំណុច ឆ រហូតដល់ចំណុច ឈ កថាខណ្ឌទី២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺសាលាដំបូងនៃនីតិវិធីសម្រេចសេចក្ដីនោះ។
- លិខិតដែលបាននៅចំណុច ង កថាខណ្ឌទី២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតុលាការ ដែលក្រឡាបញ្ជីចាត់ចែងដូចចំណុចនោះស្ថិតនៅ។
- លិខិតអនុវត្តដែលបានកំណត់នៅចំណុច ច កថាខណ្ឌទី២ មាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់ចុងចម្លើយ ដែលត្រូវបានកំណត់ដោយមាត្រា ៨ (សមត្ថកិច្ចសាលាជម្រះក្ដីដែលបានកំណត់ទៅតាមលំនៅឋានជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ បើពុំមានតុលាការដែលមានសមត្ថកិច្ចតាមមាត្រានេះ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ។

ពេលដែលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹងទៅតុលាការ។[៨]

ចំពោះនីតិវិធីនៃបណ្ដឹងតវ៉ាចំពោះការផ្ដល់រូបមន្តអនុវត្តនេះ គឺដូចគ្នានឹងនីតិវិធីធម្មតាដែរ មានន័យថា ពាក្យបណ្ដឹងតាមបញ្ញត្តិមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ ហើយក្រោយពីបានទទួល និងពិនិត្យលើពាក្យបណ្ដឹងរួចហើយ ពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយ ហើយធ្វើនីតិវិធីត្រៀមសំរាប់ការទាញហេតុផល និង នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ហើយឈានទៅដល់ការចេញសាលក្រម។

[៨] មាត្រា ៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ការអនុវត្តដោយបង្ខំមិនផ្អាកដោយស្វ័យប្រវត្តិនោះទេ ទោះបីជាក្រោយពេលកូនបំណុលដែលដើមចោទ បានដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តរួចហើយក៏ដោយ កូនបំណុលដែលជាដើមចោទក៏ត្រូវដាក់ពាក្យសុំឲ្យផ្អាកការអនុវត្តដោយបង្ខំមួយទៀតដែរ។ [9] ហើយក្រោយពេលដែលតុលាការចេញដីការបង្គាប់ឲ្យផ្អាកការអនុវត្ត កូនបំណុលដែលជាដើមចោទនោះ ត្រូវយកដីការសម្រេចនោះទៅតុលាការអនុវត្ត។[10]

### ១.៣.៣. សាលក្រម

ក្រោយពេលបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចហើយ តុលាការត្រូវចេញសាលក្រមដោយទទួលស្គាល់នូវការទាមទារ ឬ ច្រានចោលការទាមទាររបស់កូនបំណុល។ រីឯខ្លឹមសារនៃសាលក្រម គឺត្រូវសរសេរដូចគ្នាទៅនឹងការទាមទាររបស់កូនបំណុលដដែល គ្រាន់តែទទួលស្គាល់ ឬ មិនទទួលស្គាល់តែប៉ុណ្ណោះ។

ដោយសារតែសាក្រមអំពីបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តមានអនុភាព តែក្រោយពេលដែលសាក្រមនោះចូលជាស្ថាពរ ដីកាសម្រេចដោយផ្អែកតាមមាត្រា៣៦៨ គឺមានភាពចាំបាច់ដើម្បីផ្តល់នូវការសង្គ្រោះជាបណ្តោះអាសន្នចំពោះភាគីដែលឈ្នះក្តីរហូតដល់សាលក្រមចូលជាស្ថាពរ។

ពេលសាលក្រមចូលជាស្ថាពរ កូនបំណុលនៃការអនុវត្តអាចផ្អាក ឬ លុបចោលនូវការអនុវត្តដោយដាក់សាលក្រមនេះទៅស្ថាប័នអនុវត្ត[11] ពេលដែលសាលក្រមចូលជាស្ថាពរហើយម្ចាស់បំណុលនៃការអនុវត្តលែងមានសិទ្ធិដាក់ពាក្យសុំឲ្យអនុវត្តចំពោះទ្រព្យសម្បត្តិដទៃផ្សេងទៀត ដោយផ្អែកលើលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេសនេះទៀតហើយ ពីព្រោះបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្តដកចេញនូវអំណាច (អានុភាពអនុវត្ត) នៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេសនោះ។

ទោះបីជាសាលក្រមចូលជាស្ថាពរហើយក៏ដោយ ម្ចាស់បំណុលនៃការអនុវត្តនៅតែអាចបង្ហាញអង្គហេតុដែលថា លក្ខខណ្ឌបង្អង់ត្រូវបានបំពេញជាអាទិ៍ ម្តងទៀតហើយទទួលបានរូបមន្តអនុវត្តមួយផ្សេងទៀត ហើយដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ ព្រោះបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្ត

[៩] មាត្រា ៣៦៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[១០] មាត្រា ៣៧០ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[១១] មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អនុវត្តមិនដកចេញនូវអំណាច(អានុភាពអនុវត្ត) នៃលិខិតអនុវត្តដែលមានអានុភាព ប៉ុន្តែគ្រាន់តែដកចេញនូវអំណាច(អានុភាពអនុវត្ត) នៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយរូបមន្តអនុវត្តពិសេសនេះ។

## ១.៤. បណ្ដឹងជំទាស់ និងការតវ៉ាចំពោះការអនុវត្ត

បណ្ដឹជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់។ បណ្ដឹងប្រភេទនេះអាចធ្វើទៅបានលុះត្រាក្នុងករណី ដែលការចាត់ចែង ការអនុវត្ត ត្រូវបានធ្វើឡើងដោយតុលាការអនុវត្ត (មិនមែនដោយអាជ្ញាសាលានោះទេ) និងមានបញ្ញត្តិច្បាប់។[12]

ការតវ៉ា គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការនៃថ្នាក់ដដែល។ ការតវ៉ានេះអាចធ្វើនៅពេលណាក៏បាន ឲ្យតែមានផលប្រយោជន៍ក្នុងការតវ៉ា មិនកំណត់អំឡុងពេលដូចបណ្ដឹងជំទាស់ទេ។

នីតិវិធីនៃការអនុវត្ត បណ្ដឹងជំទាស់ និងការតវ៉ា ត្រូវបានបញ្ញត្តិច្បាប់អនុញ្ញាតឲ្យធ្វើក្នុងករណីដែលការចាត់ចែងនីតិវិធីនៃការអនុវត្តរបស់ស្ថាប័នអនុវត្តខុសនីតិវិធីច្បាប់។ ករណីដែលតុលាការអនុវត្តចាត់ចែងនីតិវិធីនៃការអនុវត្តដោយខុសច្បាប់ បុគ្គលដែលទទួលរងនូវការខូចប្រយោជន៍ ឬ បាត់បង់សិទ្ធិដោយសារការចាត់ចែងនីតិវិធី នៃការអនុវត្តដោយខុសច្បាប់នោះអាចដាក់ពាក្យបណ្ដឹងជំទាស់បាន បើការចាត់ចែងនីតិវិធីនៃការអនុវត្តដោយខុសច្បាប់នោះ បញ្ញាត្តិច្បាប់កំណត់ថា អាចប្ដឹងជំទាស់បាន។ ផ្ទុយទៅវិញ បើការចាត់ចែងនីតិវិធីនៃការអនុវត្តដោយខុសច្បាប់នោះ ច្បាប់មិនបានកំណត់ថា អាចប្ដឹងជំទាស់បានទេ បុគ្គលដែលខាតប្រយោជន៍ ឬ បាត់បងសិទ្ធិដោយសារការចាត់ចែងនីតិវិធីនៃការអនុវត្តដោយខុសច្បាប់ អាចដាក់ពាក្យសុំតវ៉ា ចំពោះការចាត់ចែងនីតិវិធីនៃការអនុវត្តដោយ ខុសច្បាប់ទៅតុលាការអនុវត្ត ឬ សលាដំបូងដែលមានសមត្ថកិច្ចបាន។

ជារួមការតវ៉ា គឺជាវិធីមួយដែលស្រួលធ្វើ និងរហ័សជាងបណ្ដឹងជំទាស់ ហើយវាគ្រាន់តែជានីតិវិធីបន្ថែមលើបណ្ដឹងជំទាស់ប៉ុណ្ណោះ[13] មានន័យថាការតវ៉ា និងត្រូវអនុញ្ញាតឲ្យធ្វើករណីតែខុសនីតិវិធីច្បាប់ណាមួយដែលបញ្ញត្តិច្បាប់មិនអនុញ្ញាតឲ្យធ្វើបណ្ដឹងជំទាស់។

## ១.៥. ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

ការចែកចំណែកជាវិធីចុងក្រោយនៃនីតិវិធីអនុវត្តដោយបង្ខំ។ ពេលចែកចំណែកចប់ នីតិវិធីនៃការអនុវត្តដោយបង្ខំក៏ត្រូវបញ្ចប់ដែរ។ ការចែកចំណែកត្រូវធ្វើពេលនីតិវិធីនៃការចែកចំណែកតែម្ដង។

---

[១២] មាត្រា ២៥៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[១៣] មាត្រា ៣៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បើបុគ្គលណាមួយដែលមានការមិនពេញចិត្តនឹងការចែកចំណែក គាត់ត្រូវតវ៉ាចំពោះការចែកចំណែកនៅពេលនោះ។ បន្ទាប់មកត្រូវដាក់ពាក្យបណ្ដឹងតវ៉ាចំពោះតារាងចែកចំណែកដើម្បីឲ្យតុលាការចេញសេចក្ដីសម្រេច។

គោលបំណងនៃការតវ៉ាចំពោះការចែកចំណែក គឺដើម្បីរារាំង ឬ ទប់ស្កាត់កុំឲ្យមានការចែកចំណែករហូតដល់តុលាការចេញសេចក្ដីសម្រេចអំពីចំនួនប្រាក់ចំណែកនោះ[14]។

ម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យ ចំពោះសិទ្ធិលើបំណុល ឬ ចំនួនប្រាក់ចំណែក របស់ម្ចាស់បំណុលម្នាក់ៗ ដែលត្រូវសរសេរលើតារាង ចែកចំណែកអាចថ្លែងសេចក្ដីតវ៉ាបាន នូវកាលបរិច្ឆេទ នៃការចែកចំណែក។ ដូចនេះ យើងអាចសង្កេតបានថា អ្នកដែលអាចតវ៉ាចំពោះការចែកចំណែក គឺជាម្ចាស់បំណុល ឬ ជាកូនបំណុល ដែលមិនពេញចិត្តនឹងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ឬ ចំនួនទឹកប្រាក់នៃការចែកចំណែក។

ការបរិច្ឆេទនៃការចែកចំណែក គឺពេលដែលគាត់ (ម្ចាស់បំណុល ឬ កូនបំណុល) អាចថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកបាន បើពុំដូចនោះទេគាត់នឹងបាត់បង់ឱកាសប្ដឹងតវ៉ាហើយ ព្រោះការចែកចំណែកនឹងត្រូវបញ្ចប់មាត្រា ៩៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

តុលាការដែលត្រូវអនុវត្តការចែកចំណែក គឺសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ឬ តុលាការអនុវត្តចំពោះករណីផ្សេងទៀត។ យើងអាចបែងចែកសមត្ថកិច្ចអំពីការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកជាពីរគឺៈ

- ការអនុវត្តចំពោះចលនវត្ថុ: សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ
- ការអនុវត្តផ្សេងទៀត: តុលាការអនុវត្ត

ពន្ធដាក់ពាក្យសុំ គឺមិនតម្រូវឲ្យមានទេ ពីព្រោះការតវ៉ានេះ គឺមិនមែនជាការដាក់ពាក្យសុំទៅតុលាការដើម្បីឲ្យសម្រេចសេចក្ដីនោះទេ។[15]

មូលហេតុណាក៏ដោយ ដែលមានផលប៉ះពាល់ដល់អត្ថិភាពនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ឬចំនួនប្រាក់ចំណែក ដែលបានសរសេរលើតារាងចែកចំណែក អាចជាមូលហេតុនៃការតវ៉ាដរាបណាឲ្យតែមានផលប្រយោជន៍ក្នុងការតវ៉ា។

[14] មាត្រា៩៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[15] មាត្រា ៦១ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ហើយមូលហេតុនៃការតវ៉ា មិនចាំបាច់បញ្ជាក់នៅក្នុងការតវ៉ានៅពេលនេះទេ ពីព្រោះបុគ្គលដែលបានថ្លែងតវ៉ា ត្រូវដាក់ពាក្យបណ្តឹង ហេតុនេះមូលហេតុត្រូវបានបញ្ជាក់ក្នុងពាក្យបណ្តឹងនោះហើយ។

### ១.៥.១. ផលប្រយោជន៍នៃការតវ៉ា

#### ក. ការតវ៉ាដោយម្ចាស់បំណុល

ទំហំនៃការតវ៉ាដែលម្ចាស់បំណុលអាចធ្វើបាន គឺត្រូវបានកម្រិតចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលដែលម្ចាស់បំណុលមាន ក្រោយពីការចែកចំណែក។ ហើយការតវ៉ាចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលផ្សេងទៀតដែលលើសពីចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល គឺផ្ទុយនឹងច្បាប់ ព្រោះថា ការតវ៉ានោះ គឺខ្វះផលប្រយោជន៍នៃការតវ៉ា។ ប៉ុន្តែភាពស្របច្បាប់នៃការតវ៉ាត្រូវបានចាត់ទុកថា ឯករាជ្យពីការតវ៉ាចំពោះភាគីផ្សេងទៀត។

#### ខ. ការតវ៉ាដោយកូនបំណុល

ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកដោយកូនបំណុល នាំឲ្យមានផលប្រយោជន៍ពីរគឺ៖

- ដើម្បីបង្កើនការចែកចំណែកទៅឲ្យម្ចាស់បំណុលពិតប្រាកដ
- ដើម្បីកុំឲ្យចែកចំណែកទៅឲ្យម្ចាស់បំណុលខុស

បើកូនបំណុលតវ៉ាចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលណាមួយ ហើយដាក់ពាក្យបណ្តឹង ចំណែករបស់ម្ចាស់បំណុលនោះនឹងត្រូវបានផ្អាកជាបណ្តោះអាសន្នសិន[16] រងចាំរហូតដល់មានសេចក្តីសម្រេចពីការតវ៉ា ទើបអាចធ្វើការបែងចែកលើចំណែកដែលបានផ្អាកនោះបាន។ ប៉ុន្តែការតវ៉ារបស់កូនបំណុលចំពោះម្ចាស់បំណុលណាមួយនោះ វាមិនបណ្តាលឲ្យប៉ះពាល់ទៅដល់ការបែងចែកចំណែករបស់ម្ចាស់បំណុលផ្សេងៗទៀតទេ។[17]

ចំពោះការតវ៉ាលើតារាងចំណែក បើកូនបំណុលឈ្នះក្នុងការតវ៉ា ចំណែកដែលតវ៉ានឹងត្រូវបានបែងចែកទៅឲ្យម្ចាស់បំណុលដទៃទៀត។ តុលាការដែលត្រូវអនុវត្តការបែងចែកចំណែកត្រូវធ្វើការផ្លាស់

---

[១៦] មាត្រា ៥៩៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[១៧] មាត្រា៥៩១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ប្តូរតារាងថ្មីដើម្បីឲ្យម្ចាស់បំណុលដែលមិនបានធ្វើសេចក្តីថ្លែងការណ៍តវ៉ាចំពោះការសរសេរលើតារាង បានទទួលការបែងចែកចំណែកដែរ[18]។

ដូចនេះកូនបំណុលអាចបញ្ចៀសនូវការចែកចំណែកទៅឲ្យម្ចាស់បំណុលក្លែងក្លាយ ហើយ អាចបង្កើតនូវការចែកចំណែកទៅឲ្យម្ចាស់បំណុលពិតប្រាកដ។ ផ្ទុយទៅវិញ បើកូនបំណុលចាញ់ក្នុងការតវ៉ាចំណែកដែលតវ៉ានឹងត្រូវបែងចែកទៅឲ្យម្ចាស់បំណុលដដែល ដោយមិនមានការផ្លាស់ប្តូរតារាងថ្មីនោះទេ។

### ១.៥.២.នីតិវិធីការតវ៉ា

ម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តដែលមានឧបាស្រ័យចំពោះសិទ្ធិលើបំណុល ឬចំនួនប្រាក់ចំណែករបស់ម្ចាស់បំណុលម្នាក់ៗ ដែលត្រូវបានសរសេរលើតារាងចំណែកចែក អាចថ្លែងសេចក្តីតវ៉ាបាននូវកាលបរិច្ឆេទ នៃការបែងចែកចំណែក (ការតវ៉ាអាចធ្វើឡើងដោយផ្ទាល់មាត់ ឬដោយដាក់ជាឯកសារ) ក្នុងការតវ៉ានេះកូនបំណុលត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលតវ៉ា ដើម្បីឲ្យតុលាការងាយស្រួលធ្វើការបែងចែកចំណែកដែលគ្មានការតវ៉ា។ ផ្ទុយទៅវិញ មូលហេតុនៃការតវ៉ាមិនចាំបាច់បញ្ជាក់ពេលថ្លែងការណ៍នោះទេ តែចាំបាច់ត្រូវតែសរសេរបញ្ជាក់ពីមូលហេតុនៅក្នុងបណ្តឹងតវ៉ាដែលបានដាក់មកតុលាការ។[19]

ការតវ៉ារបស់កូនបំណុលបានកំណត់ថា បើពាក្យបណ្តឹងតវ៉ាមិនបានដាក់ទៅតុលាការក្នុងអំឡុងពេលមួយសប្តាហ៍ ចាប់ពីកាលបរិច្ឆេទបែងចែកចំណែកនោះទេ ការតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវចាត់ទុកថាបានដកមកវិញ។

## ១.៦. បណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក

បណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមានពីរប្រភេទ៖

- បណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកដោយម្ចាស់បំណុល ចំពោះម្ចាស់បំណុលផ្សេងទៀត។[20]

[18] មាត្រា ៤៩៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[19] មាត្រា៤៩១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[20] មាត្រា ៤៩២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

- បណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកដោយកូនបំណុល ចំពោះម្ចាស់បំណុលដែលមិនមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។[21]

ផ្ទុយទៅវិញ ក្នុងករណីដែលម្ចាស់បំណុលមានលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ដោយបង្ខំបណ្ដឹងចាំបាច់សំរាប់កូនបំណុលដែលបានថ្លែងតវ៉ា គឺបណ្ដឹងតវ៉ាចំពោះការទាមទារ ពីព្រោះថា គោលគំនិតច្បាប់គឺថា មានតែបណ្ដឹងតវ៉ាចំពោះការទាមទារតែមួយប៉ុណ្ណោះ ដែលជាមធ្យោបាយសំរាប់តវ៉ានឹងអានុភាពនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។

## ១.៦.១. គោលបំណងនៃបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងបែងចែកចំណែក

បណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងបែងចែកចំណែកដោយម្ចាស់បំណុល ចំពោះម្ចាស់បំណុលផ្សេងទៀត ហើយការតវ៉ារបស់ម្ចាស់បំណុលនេះ គឺដើម្បីបង្កើនចំនួនប្រាក់ចំណែកដែលគាត់បានទទួលពីការបែងចែក។ រីឯម្ចាស់បំណុលដែលមិនបានធ្វើការតេវ៉ា គឺគ្មានសិទ្ធិទទួលបានចំណែកនោះទេ ទោះបីជានៅពេលដែលម្ចាស់បំណុលដែលបានតវ៉ាឈ្នះក្ដីក៏ដោយ។

បណ្ដឹងតវ៉ារបស់កូនបំណុលចំពោះម្ចាស់បំណុលផ្សេងទៀត ការតវ៉ានេះ គឺដើម្បីបង្កើនចំនួនក្នុងការបែងចែកទៅឱ្យម្ចាស់បំណុលពិតប្រាកដ ហើយដើម្បីជៀសវាងការចែកចំណែកខុស។

- **បណ្ដឹងតវ៉ាដោយម្ចាស់បំណុល**

  ដើមចោទ: គឺជាម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ា

  ចុងចម្លើយ: គឺជាម្ចាស់បំណុលម្ខាងទៀតនៃពាក្យសុំតវ៉ា

- **បណ្ដឹងតវ៉ាដោយកូនបំណុល**

  ដើមចោទ: គឺកូនបំណុលដែលបានធ្វើសេចក្ដីតវ៉ាចំពោះម្ចាស់បំណុល

  ចុងចម្លើយ: គឺម្ចាស់បំណុលដែលមិនមានឯកសារយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។

កូនបំណុល និងម្ចាស់បំណុលដែលបានថ្លែងសេចក្ដីតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវដាក់ពាក្យបណ្ដឹងតវ៉ាក្នុងអំឡុងពេលមួយសប្ដាហ៍ ហើយមិនបានដាក់ក្នុងអំឡុងពេលនេះទេ ការតវ៉ានេះនឹងចាត់ទុកថាបានដកវិញ។[22]

[២១] មាត្រា ៥៩៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[២២] មាត្រា ៥៩២ កថាខណ្ឌទី៣ និងមាត្រា ៥៩៣ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦។

### ១.៦.២.សមត្ថកិច្ច

បណ្តឹងតវ៉ា ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលត្រូវអនុវត្តការបែងចែក។ ផ្ទុយទៅវិញ បើបណ្តឹងតវ៉ាត្រូវបានដាក់ទៅតុលាការដែលគ្មានសមត្ថកិច្ច តុលាការនេះ ត្រូវធ្វើការផ្ទេរទៅឱ្យតុលាការដែលមានសមត្ថកិច្ច ព្រោះបណ្តឹងនេះ ដូចគ្នានឹងបណ្តឹងធម្មតាដែរ។[23]

ការកំណត់អំពីពន្ធដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ត្រូវអនុលោមតាមមាត្រា ៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាបទបញ្ញត្តិទូទៅ។ ហេតុនេះ ចាំបាច់ត្រូវកំណត់ពីតម្លៃនៃកម្មវត្ថុបណ្តឹងមុនសិន ទើបអាចកំណត់ពន្ធសម្រាប់ការដាក់ពាក្យបណ្តឹងនេះបាន។

ដើម្បីចាត់ការលើបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក តុលាការត្រូវអនុវត្តតាមនីតិវិធីនៃបណ្តឹងធម្មតា មានន័យថា ត្រូវឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ មុននឹងឈានទៅដល់ការចេញសាលក្រមចុងក្រោយ។

លក្ខណៈពិសេស ដែលគួរឱ្យកត់សម្គាល់នៅត្រង់ចំណុចនេះ គឺថាពាក្យបណ្តឹងតវ៉ាត្រូវដាក់ក្នុងអំឡុងពេលមួយសប្តាហ៍ ចាប់ពីកាលបច្ឆេទនៃការចែកចំណែក។ ក្នុងករណីនេះ តុលាការដែលត្រូវអនុវត្តការចែកចំណែក ត្រូវតែធ្វើការចែកចំណែកជាធម្មតា។

នៅក្នុងពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារគឺ:

- អត្ថិភាពនៃតារាងចែកចំណែកដែលជាកម្មវត្ថុនៃការតវ៉ា
- និងអត្ថិភាពនៃចំនួនទឹកប្រាក់ចំណែកដែលជាកម្មវត្ថុនៃការតវ៉ា។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺអត្ថិភាពនៃបណ្តឹងតវ៉ា និងចំនួនទឹកប្រាក់ចំណែកនៃការតវ៉ា។ អង្គហេតុអំពីអត្ថិភាពនៃសិទ្ធិលើបំណុល ពុំមែនជាអង្គហេតុដែលជាមូលហេតុនៃការទាមទារទេ តែអង្គហេតុតវ៉ា។ ហេតុនេះ កាលបើកូនបំណុលដាក់ពាក្យបណ្តឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែក ម្ចាស់បំណុលដែលជាភាគីចុងចម្លើយនៅក្នុងពាក្យបណ្តឹងតវ៉ាត្រូវអះអាង និងបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ខ្លួន មិនមែនកូនបំណុលជាអ្នកអះអាង និងបញ្ជាក់ពីនត្ថិភាព នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលជាភាគីចុងចម្លើយឡើយ។ អានុភាពនៃលិខិតអនុវត្ត ចងតែភាគីដែលពាក់ព័ន្ធតែប៉ុណ្ណោះ។

[២៣] មាត្រា ១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុដូច្នេះ នៅក្នុងបណ្ដឹងរវាងម្ចាស់បំណុល វាមិនមានបញ្ហាចោទនោះទេ ករណីប្រសិនបើ ចុងចម្លើយមានលិខិត អនុវត្តចំពោះកូនបំណុល។ ម្ចាស់បំណុលជាដើមចោទនៅតែអាចតវ៉ាចំពោះអត្ថិភាព និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលដែលជាចុងចម្លើយ ហើយម្ចាស់បំណុលដែលជាចុងចម្លើយ នៅតែត្រូវធ្វើការបញ្ជាក់អំពីអត្ថិភាព និងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលចំពោះដើមចោទដែលជាម្ចាស់បំណុល។

**១.៦.៣. សាលក្រម**

ប្រសិនបើតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ តុលាការលុបចោលចំនួនទឹកប្រាក់នៃចំណែករបស់ចុងចម្លើយដែលបានសរសេរនៅលើតារាងចែកចំណែក ឬ កែប្រែតារាងចែកចំណែកនោះ និងកំណត់អំពីវិធីបំពេញចំនួនទឹកប្រាក់នៃចំណែកនោះ ដើម្បីបែងចែកបន្ថែមទៅឱ្យម្ចាស់បំណុលដទៃទៀតនៅក្នុងសាលក្រម។ ប៉ុន្តែ ក្នុងករណីដែលចំនួនទឹកប្រាក់ដែលត្រូវបែងចែកបន្ថែម មិនអាចកំណត់បាន ដោយសារមានបណ្ដឹងតវ៉ាចំពោះការសរសេរលើតារាងចែកចំណែកមួយទៀត កំពុងត្រូវបានចាត់ការ នោះតុលាការ អាចលុបចោលចំនួនទឹកប្រាក់នៃចំណែករបស់ចុងចម្លើយដែលបានសរសេរនៅលើតារាងចែកចំណែក និងគ្រាន់តែបង្គាប់ឱ្យធ្វើតារាងចែកចំណែកថ្មី នៅក្នុងសាលក្រមបាន។

ប្រសិនបើ តុលាការមិនទទួលស្គាល់ការទាមទាររបស់ដើមចោទទេ តុលាការច្រានចោលការទាមទាររបស់ដើមចោទ។

# ជំពូកទី២

# លំហូរនីតិវិធីនៃ

# បណ្តឹងតវ៉ារបស់តតិយជន

# ជំពូកទី២

# លំហូរនីតិវិធីបណ្តឹងតវ៉ារបស់តតិយជន

## ២.១. គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន

គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺដើម្បីដកចេញពីការអនុវត្តដោយបង្ខំនូវកម្មវត្ថុជាក់ណាមួយពីការអនុវត្តដោយបង្ខំ។ បណ្តឹងតវ៉ារបស់តតិយជនមានសារៈសំខាន់ ពីព្រោះករណីនេះសំរាប់ស្ថាប័នអនុវត្តមិនពិនិត្យមើលថា អ្នកណាជាម្ចាស់កម្មសិទ្ធិនោះទេ ប៉ុន្តែគ្រាន់តែពិនិត្យល័ក្ខខណ្ឌទំរង់សំរាប់ចាប់ផ្តើមការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។

អ្នកដែលអាចសុំឱ្យអនុវត្តដោយបង្ខំបាន គឺអ្នកដែលមានលិខិតអនុវត្តជាសាលក្រម ឬឯកសារផ្សេងទៀតដែលបង្ហាញពីលទ្ធភាពខ្ពស់នៃអត្ថិភាពនៃមូលដ្ឋានសំរាប់ការអនុវត្តដោយបង្ខំ។ ជាទូទៅគេអាចនិយាយថា សិទ្ធិរបស់ម្ចាស់បំណុលត្រូវបានគេទទួលស្គាល់រួចហើយ ហើយសិទ្ធិនោះមានអនុភាព ដោយមិនចាំបាច់ធ្វើការពិនិត្យជាលក្ខណៈសារធាតុបន្ថែមទៀតនោះទេ។

នេះជាមូលហេតុដែលស្ថាប័នអនុវត្ត មិនពិនិត្យជាលក្ខណៈសារធាតុនូវទំនាក់ទំនងគតិយុត្តថាតើមានអត្ថិភាព ឬ នត្ថិភាពនោះទេ ហើយក៏មិនពិនិត្យ មើលថាតើកម្មវត្ថុនៃការអនុវត្តជារបស់កូនបំណុល ឬអត់នោះទេផងដែរ។ មូលហេតុដែលនាំឱ្យមានមធ្យោបាយមួយចំនួនសំរាប់តតិយជនដើម្បីដាក់ពាក្យបណ្តឹងតវ៉ា គឺដើម្បីផ្តល់ឱកាសឱ្យតតិយជនធ្វើការតវ៉ាក្នុងករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះគឺជារបស់គាត់។

បន្ទាប់មកតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀត ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិជួលអចិន្ត្រៃយ៍ជាដើម អាចដាក់ពាក្យបណ្តឹងតវ៉ាដើម្បីដកចេញ ឬលុបចោលនូវការអនុវត្តដោយបង្ខំ។ នេះហៅថា បណ្តឹងតវ៉ារបស់តតិយជន។

## ២.២. វិសាលភាពនៃបណ្តឹងតវ៉ារបស់តតិយជន

តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះដល់ការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំអាចដដាក់ពាក្យបណ្តឹងតវ៉ា[24] ដូច្នេះតតិយជន អាចដាក់ពាក្យបណ្តឹងតវ៉ាមិនត្រឹមតែចំពោះអចលនវត្ថុនោះទេ ប៉ុន្តែថែមទាំងចលនវត្ថុផងដែរ ដែលអាចដាក់ទៅស្ថាប័នអនុវត្តជាតុលាការ ឬអាជ្ញាសាលា។

២៤ មាត្រា ៣៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មានន័យថា តតិយជនអាចដាក់ពាក្យបណ្ដឹងតវ៉ា ទាំងក្នុងករណីការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ និងការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងទាមទារឱ្យសងជាប្រាក់ ។

បណ្ដឹងតវ៉ារបស់តតិយជន អាចយកទៅអនុវត្តបានចំពោះការអនុវត្តដោយបង្ខំគ្រប់ប្រភេទ ។ បណ្ដឹងនេះត្រូវបានទទួលស្គាល់ថា ជាវិធីសង្គ្រោះ មិនចំពោះតែការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ប៉ុណ្ណោះទេ តែក៏ចំពោះការអនុវត្តដោយបង្ខំឲ្យប្រគល់វត្ថុ ការអនុវត្តដោយបង្ខំឲ្យចាកចេញពីផ្ទះណាមួយជាអាទិ៍ផងដែរ។

បណ្ដឹងនេះអាចយកទៅអនុវត្តបានមិនចំពោះតែករណីដែលកម្មវត្ថុនៃការអនុវត្តដោយបង្ខំគឺជាវត្ថុរូបី ដូចជា ចលនវត្ថុ និងអចលនវត្ថុប៉ុណ្ណោះទេ តែក៏ចំពោះករណីដែលកម្មវត្ថុនៃការអនុវត្តគឺជាសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតផងដែរ។

ដោយមិនគិតអំពីប្រភេទស្ថាប័នអនុវត្ត បណ្ដឹងនេះអាចធ្វើបានមិនចំពោះតែការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្តប៉ុណ្ណោះទេ តែក៏អាចធ្វើបានចំពោះការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលាផងដែរ។

ជាងនេះទៅទៀតបណ្ដឹងនេះក៏អាចធ្វើបានដែរ នៅក្នុងករណីដែលការអនុវត្តដោយបង្ខំខុសច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំពីដំបូង ហើយដែលការតវ៉ាចំពោះការអនុវត្ត និងបណ្ដឹងជំទាស់ក៏អាចធ្វើទៅបាន។

## ២.៣. មូលហេតុនៃការតវ៉ារបស់តតិយជន

មូលហេតុដែលនាំឱ្យមានបណ្ដឹងតវ៉ារបស់តតិយជនត្រង់ចំណុចដែលថា "តតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ"[25]។

ផ្អែកតាមបញ្ញត្តិខាងលើអាចយល់បានថា មូលហេតុដែលនាំឱ្យមានបណ្ដឹងតវ៉ារបស់តតិយជនគឺការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ នឹងបំពានសិទ្ធិរបស់តតិយជន។ ក្នុងករណីនេះ យើងត្រូវបែងចែកជាពីរករណី៖

- ករណីដែលលិខិតអនុវត្តមានខ្លឹមសារឱ្យប្រគលវត្ថុ

[២៥] មាត្រា ៣៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នៅក្នុងករណីដែល សាលក្រមចុងក្រោយបានសម្រេចបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុជាក់លាក់ណាមួយឱ្យទៅម្ចាស់បំណុល។ សិទ្ធិរាំងស្ទះដល់ការប្រគល់វត្ថុនេះអាចជា សិទ្ធិកាន់កាប់ សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិជួលផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព សិទ្ធិឃាត់ទុក និងសិទ្ធិលើការបញ្ចាំ។

សិទ្ធិទាំងឡាយដែលបានរៀបរាប់ខាងលើ ធ្វើឱ្យការកាន់កាប់វត្ថុរបស់តតិយជនមានភាពត្រឹមត្រូវតាមច្បាប់ ហេតុនេះ ការប្រគល់វត្ថុទៅឱ្យម្ចាស់បំណុលនៃការអនុវត្តនាំឱ្យបំពានដល់សិទ្ធិរបស់តតិយជន។

ចំណែកឯ ហ៊ីប៉ូតែក និងឯកសិទ្ធិ ពុំមែនជាសិទ្ធិដែលរាំងស្ទះដល់ការប្រគល់ទេ។

ហេតុដែលនាំឱ្យអះអាងថា ឯកសិទ្ធិ និងហ៊ីប៉ូតែក មិនមែនជាសិទ្ធិដែលរាំងស្ទះដល់ការប្រគល់វត្ថុឱ្យម្ចាស់បំណុលនៃការអនុវត្ត គឺដោយសារតែម្ចាស់ឯកសិទ្ធិ និងម្ចាស់បំណុលហ៊ីប៉ូតែកពុំមានសិទ្ធិដោយផ្ទាល់ក្នុងការកាន់កាប់វត្ថុទេ គ្រាន់តែមានសិទ្ធិទទួលការសងពីទ្រព្យដែលជាកម្មវត្ថុនៃឯកសិទ្ធិ ឬហ៊ីប៉ូតែក ដោយមានអាទិភាពជាងម្ចាស់បំណុលដទៃទៀតប៉ុណ្ណោះ។[26]

- ក្នុងករណីដែលការអនុវត្តដោយបង្ខំ មានកម្មវត្ថុជាការលក់ដោយបង្ខំនូវអចលនវត្ថុជាក់លាក់ណាមួយវិញនោះ តតិយជនដែលមានកម្មសិទ្ធិលើវត្ថុ អាចយកមូលហេតុមកសំអាងដើម្បីតវ៉ាកុំឱ្យមានការអនុវត្តដោយបង្ខំ ព្រោះថា ការអនុវត្តដោយបង្ខំនឹងធ្វើឱ្យខ្លួនបាត់បង់នូវកម្មសិទ្ធិលើវត្ថុ។ ផ្ទុយទៅវិញប្រសិនបើតតិយជន មានត្រឹមតែសិទ្ធិកាន់កាប់ សិទ្ធិលើការបញ្ចាំ ផលុបភោគជាអាទិ៍ ការលក់ដោយបង្ខំនូវអចលនវត្ថុ មិនបណ្តាលឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជនឡើយ។ ហេតុនេះ ការអះអាងអំពីសិទ្ធិកាន់កាប់ ឬ សិទ្ធិលើការបញ្ចាំ ឬ ផលុបភោគ មិនមែនជាមូលហេតុនៃបណ្តឹងតវ៉ារបស់តតិយជនទេ។

## ២.៣.១. បណ្តឹងតវ៉ារបស់តតិយជនដោយផ្អែកលើការភាន់ច្រឡំ

ការភាន់ច្រឡំ គឺជាការបង្ហាញឆន្ទៈដែលផ្ទុយទៅនឹងឆន្ទៈពិតរបស់ភាគី ហើយដែលភាគីមិនបានដឹងពីការបង្ហាញឆន្ទៈមិនពិតនោះក្នុងពេលបង្កើតកិច្ចសន្យា។ ការបង្ហាញឆន្ទៈត្រូវឆ្លងកាត់នូវដំណាក់កាលមួយចំនួនដូចជា ការកើតឡើងចំណង់ ឬហេតុជម្រុញឱ្យធ្វើអ្វីមួយការសម្រេចចិត្តតាមសកម្មភាព ការសម្រេចចិត្តធ្វើការបង្ហាញ ឆន្ទៈ និងដំណាក់កាលធ្វើសកម្មភាពតាមឆន្ទៈនោះ។

[26] មាត្រា ៧៨១ និងមាត្រា ៨៤៣ នៃក្រមរដ្ឋប្បវេណី

**ក- ការភាន់ច្រឡំអំពីចំណុចសំខាន់នៃកិច្ចសន្យា**

ភាគីមានការភាន់ច្រឡំទៅលើចំណុចសំខាន់ៗ នៃកិច្ចសន្យា និងភាគីម្ខាងទៀតស្ថិតក្នុងស្ថានភាពដែលអាចដឹងពីការភាន់ច្រឡំនោះ។

**ខ- ការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់**

ការភាន់ច្រឡំដែលពាក់ព័ន្ធ ចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា។[27]

**ឃ- ការភាន់ច្រឡំដោយភាគីទាំងសងខាង**

ការភាន់ច្រឡំដោយភាគីទាំងសងខាង បើតាមមាត្រា ៣៤៦ កថាខណ្ឌទី៣ ចែងថា នៅក្នុងករណីនៃការភាន់ច្រឡំដោយភាគីទាំងសងខាង អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យា ទោះបីភាគីម្ខាងទៀតមិនបានដឹងអំពីការភាន់ច្រឡំនោះក៏ដោយ។

### ២.៣.២ ការការពារតតិយជន

ការការពារតតិយជន គឺជាការចាំបាច់ ដើម្បីការពារផលប្រយោជន៍របស់គាត់ដែលកើតចេញពីការបង្កើតកិច្ចសន្យាដែលមានវិការៈនោះ។ ប្រសិនបើកិច្ចសន្យាដែលត្រូវបានលុបចោលដោយផ្អែកលើការភាន់ច្រឡំ នោះតតិយជនដែលបានបង្កើតនូវទំនាក់ទំនងនៃកិច្ចសន្យានោះ គឺទទួលរងនូវការខូចខាត។

### ២.៣.៣. គំនិតបដិសេធការអនុវត្ត

ដោយផ្អែកលើគោលគំនិតនៃមាត្រា ៣៤៦ កថាខណ្ឌទី៤ គឺដើម្បីការការពារតតិយជនដែលបានបង្កើតទំនាក់ទំនងនៃកិច្ចសន្យាមុនពេលលុបចោល។ បញ្ហាថាតើគេត្រូវធ្វើការការពារតតិយជនដែលបានបង្កើតទំនាក់ទំនងកិច្ចសន្យានៅក្រោយការលុបចោលយ៉ាងដូចម្តេច? មានគំនិតមួយចំនួនដែលអាចគិតបានដូចជា៖

**ក- គំនិតដែលទទួលស្គាល់ដូចករណីលក់ជាន់គ្នា**

ដោយផ្អែកលើគំនិតនេះ គឺមានការផ្ទេរកម្មសិទ្ធិចំនួនពីរ គឺការលក់ពីរដង ឬការលក់ជាន់គ្នា។ បើតាមគោលគំនិតនៃមាត្រា ១៣៥ មិនត្រូវបានយកមកអនុវត្តទេ ព្រោះការផ្ទេរកម្មសិទ្ធិនេះមិនបាន

[២៧] មាត្រា ៣៤៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ផ្អែកលើការព្រមព្រៀងនោះទេ។ ដូច្នេះ ភាគីដែលទទួលនូវលក្ខខណ្ឌតតាំង អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន ដោយផ្អែកលើ។

**ខ- គំនិតដែលអនុវត្ត**

កិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិត ដែលត្រូវធ្វើឡើងដោយមានការឃុបឃិតគ្នាជាមួយភាគីម្ខាងទៀតត្រូវចាត់ទុកជាមោឃៈ ក៏ប៉ុន្តែគេមិនអាចអះអាងចំពោះតតិយជនដែលសុចរិត និងគ្មានកំហុតដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។[28]

## ២.៣.៤. បណ្តឹងតវ៉ារបស់តតិយជនដោយផ្អែកលើការឆបោក

ការឆបោក គឺភាគីនៃកិច្ចសន្យា ឬ តតិយជន បានបង្ហាញឆន្ទៈមានការភាន់ច្រឡំ ដោយមានការប្រើមធ្យោបាយឆបោក ហើយដែលភាគី ឬ តតិយជននោះមិនបានដឹងពីការឆបោក នោះនៅពេលដែលខ្លួនចុះកិច្ចសន្យា។ លក្ខខណ្ឌដើម្បីកំណត់ថាជាការឆបោកនោះគឺៈ

- ភាគីម្ខាងទៀតមានគោលបំណងឆបោក
- សកម្មភាពឆបោកនោះត្រូវបានទទួលស្គាល់ថាខុសច្បាប់
- អ្នកបង្ហាញឆន្ទៈបានភាន់ច្រឡំដោយសារសកម្មភាពឆបោក
- អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈដោយមានវិការៈ ដោយសារតែការភាន់ច្រឡំនោះ។

គោលបំណងឆបោក សំដៅទៅលើភាគីម្ខាងទៀត មានគោលបំណងធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ និងបង្ហាញឆន្ទៈដែលមានវិការៈ ដោយសារតែការភាន់ច្រឡំ។ គោលបំណងធ្វើឱ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ មានន័យថា ភាគីម្ខាងទៀត ឬ តតិយជន បានដឹងថាសកម្មភាពរបស់ខ្លួន គឺជាសកម្មភាពឆបោក និងអ្នកដែលបង្ហាញឆន្ទៈ និងមានការភាន់ច្រឡំដោយសារតែសកម្មភាពឆបោករបស់ខ្លួន នោះ។

ភាពខុសច្បាប់នៃការឆបោក មានន័យថា សកម្មភាពឆបោករបស់ភាគីម្ខាងទៀតត្រូវតែជាសកម្មភាពផ្ទុយច្បាប់ ហើយដែលមិនអាចទទួលយកបានក្នុងសង្គម។

---

[២៨] មាត្រា ៣៥៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ដើម្បីចាត់ទុកជាការឆបោក គឺតម្រូវឱ្យមានអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ដោយសារការឆបោករបស់ភាគីម្ខាងទៀត។ ដូច្នេះ នៅក្នុងករណីនៃការឆបោក ភាពចាំបាច់ក្នុងការការពារបង្ហាញអ្នកឆន្ទៈ គឺខ្ពស់ជាងករណីនៃការភាន់ច្រឡំ។

### ២.៣.៥. បណ្ដឹងតវ៉ារបស់តតិយជនដោយផ្អែកលើការរំលោភបំពានលើស្ថានភាព

ការរំលោភបំពាន់លើស្ថានភាព គឺជាករណីដែលភាគីបានបង្កើតកិច្ចសន្យាដោយឈ្លៀតឱកាស ដែលភាគីម្ខាងទៀត កំពុងជួបប្រទះនូវស្ថានភាពចាំបាច់ ទន់ខ្សោយ ឬ ជួបនូវលំបាក់ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ ជាការប្រើប្រាស់ដោយមិនត្រឹមត្រូវនូវសកម្មភាពដទៃទៀត ដែលភាគីនោះ មិនមានលទ្ធភាពក្នុងការប្រឆាំងតបតបាន។ នៅក្នុងករណីនេះ ភាគីដែលបានរំលោភបំពានលើស្ថាន មិនត្រូវបានចាត់ទុកថា បានគំរាមកំហែងឡើយ ពីព្រោះគាត់មិនប្រើវិធានការបង្ខំ។ ប៉ុន្តែ ដើម្បីបង្កើតជាការរំលោភលើស្ថានភាព វាមានភាពចាំបាច់ដែលភាគីម្ខាងទៀតឈ្លៀតឱកាសនៃស្ថានភាពទន់ខ្សោយនៃអ្នកបង្ហាញឆន្ទៈ។ មានលក្ខខណ្ឌចំនួន៣ ក្នុងករណីនេះដូចជា៖

- អ្នកបង្ហាញឆន្ទៈ ស្ថិតក្នុងស្ថានភាពដែលមានការលំបាកក្នុងការបដិសេដចំពោះការទាមទាររបស់ភាគីម្ខាងទៀត ព្រោះភាគីម្ខាងទៀត បានប្រើអំណាចខាងផ្នែកសេដ្ឋកិច្ច ឬ ឋានៈនៃសង្គមជាអាទិ៍ ដែលមានលក្ខណៈខ្ពស់ជាង
- ភាគីម្ខាងទៀតប្រើឋានៈរបស់ខ្លួន ដើម្បីទទួលបាននូវផលប្រយោជន៍មិនត្រឹមត្រូវ
- អ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួន ព្រោះគាត់មិនអាចបដិសេធបាននូវការទាមទាររបស់ភាគីម្ខាងទៀត ដោយសារឋានៈរបស់ខ្លួនទាបជាង។

ដូច្នេះ ភាគីដែលបង្ហាញឆន្ទៈ ដោយការរំលោភលើស្ថានភាពអាចលុបចោលនៃកិច្ចសន្យានោះបាន។ ប៉ុន្តែ ការលុបចោលកិច្ចសន្យានេះ មិនអាចអះអាង តតិយជនដែលសុចរិត និងគ្មានកំហុសបានឡើយ។

## ២.៤. លក្ខណៈជាភាគី

តតិយជនដែលដាក់ពាក្យបណ្ដឹងតវ៉ាត្រូវបានហៅថា ដើមចោទរឹងចុងចំលើយគឺជាម្ចាស់បំណុលនៃលិខិតអនុវត្ត។

បុគ្គលដែលមានលក្ខណៈជាដើមចោទ ដែលអាចដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជនបាន គឺតតិយជនដែលអះអាងថា ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុណាមួយ បំពានលើសិទ្ធិរបស់ខ្លួន (កម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀត)។

កូនបំណុលនៃការអនុវត្ត ពុំមានលក្ខណៈជាដើមចោទដែលអាចដាក់ពាក្យបណ្ដឹងនេះបានទេ បើទោះបីជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ មិនមែនជាទ្រព្យសម្បត្តិរបស់ខ្លួនក៏ដោយ។ ក៏ប៉ុន្តែក្នុងករណីមានការរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន បើទោះជានៅក្នុងលិខិតអនុវត្តមានការសរសេរថា "ត្រូវសងត្រឹមទំហំនៃទ្រព្យសម្បត្តិដែលបានទទួលតាមរយៈសន្តតិកម្ម" ក៏ដោយនោះសន្តតិជនអាចដាកពាក្យបណ្ដឹងតវ៉ារបស់តតិយជនបាន ព្រោះថាក្នុងករណីនេះឋានៈរបស់សន្តតិជននោះនៅក្នុងទំនាក់ទំនងទៅនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនមានលក្ខណៈប្រហាក់ប្រហែលទៅនឹងតតិយជនដែរ។

បុគ្គលដែលមានលក្ខណៈជាចុងចំលើយ គឺម្ចាស់បំណុលនៃការអនុវត្ត មិនមែនអាជ្ញាសាលា ឬស្ថាប័នអនុវត្តផ្សេងទៀតទេ។ ពុំមានភាពចាំបាច់ដែលត្រូវឲ្យកូនបំណុលនៃការអនុវត្តធ្វើជាចុងចម្លើយនៅក្នុងករណីនេះទេ។

## ២.៥. ពេលដែលអាចដាក់បណ្ដឹងតវ៉ារបស់តតិយជន

ជាគោលការណ៍ គោលបំណងនៃការរារាំងដើម្បីទាមទារកុំឱ្យមានការអនុវត្តដោយបង្ខំលើវត្ថុជាក់លាក់ណាមួយនោះ គឺដើម្បីការពារសិទ្ធិរបស់តតិយជននោះ មានន័យថា បណ្ដឹងតវ៉ារបស់តតិយជនអាចត្រូវបានដាក់ដើម្បីកុំឱ្យមានការអនុញ្ញាតការអនុវត្តដោយបង្ខំ ក្រោយពេលដែលវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ត្រូវគេបញ្ជាក់ច្បាស់លាស់ហើយ ឬនៅពេលចាប់ផ្ដើមអនុវត្តដោយបង្ខំ។

ជាអញ្ញត្រកម្មទៅនឹងគោលការណ៍ខាងលើនេះ យើងសង្កេតឃើញថា ក្នុងករណីមួយចំនួនទោះបីជាការអនុវត្តដោយបង្ខំមិនទាន់បានចាប់ផ្ដើមក៏ដោយ ក៏យើងអាចកំណត់បានយ៉ាងច្បាស់នូវទ្រព្យសម្បត្តិដែលនឹងក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ ឧបមាថា នៅក្នុងសាលក្រមចុងក្រោយមួយ មានខ្លឹមសារបង្គាប់ឱ្យចុងចំលើយប្រគល់ទ្រព្យសម្បត្តិណាមួយទៅឱ្យដើមចោទ ដូច្នេះយើងអាចដឹងជាមុន ហើយថាតើទ្រព្យសម្បត្តិណាមួយដែលនឹងក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះ ទោះបីជាការអនុវត្តដោយបង្ខំនោះមិនទាន់ត្រូវបានចាប់ផ្ដើមនៅឡើយក៏ដោយ ដរាបណា

ឱ្យតែតតិយជននោះមានផលប្រយោជន៍ក្នុងការប្ដឹងដោយផ្អែកលើតាមមាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផលប្រយោជន៍នៃបណ្ដឹងក្នុងករណីនេះគឺសំដៅទៅលើ "លទ្ធភាពនៃការអនុវត្តដោយបង្ខំ" ។ ដូច្នេះ ករណីប្រសិនបើ ម្ចាស់បំណុលនៃការអនុវត្តបានទទួលរូបមន្តអនុវត្តហើយ គឺមានន័យថាសាលក្រមនេះនឹងអាចយកទៅអនុវត្តដោយបង្ខំបានហើយ។ ក៏ប៉ុន្តែ ករណីប្រសិនបើ សាលក្រមមិនទាន់ចូលជាស្ថាពរ ហើយមិនមាន អនុភាពអនុវត្តនៅឡើយទេ តតិយជនមិនមានផលប្រយោជន៍នៅក្នុងបណ្ដឹងតវ៉ានោះទេ។

ក្នុងករណីដែល សាលក្រមមិនទាន់ចូលជាស្ថាពរនៅឡើយទេ តតិយជនអាចប្រើមធ្យោបាយផ្សេងទៀតដែលច្បាប់អនុញ្ញាតឲ្យដើម្បីការពារសិទ្ធិរបស់ខ្លួន ដូចជាតាមរយៈ ការធ្វើសហាបណ្ដឹង។[29]

បណ្ដឹងតវ៉ារបស់តតិយជនត្រូវធ្វើមុនការបញ្ចប់ការអនុវត្ត ប្រសិនបើការអនុវត្តដោយបង្ខំបានចប់សព្វគ្រប់ហើយ សិទ្ធិរបស់តតិយជនត្រូវបានគេបំពាន ក្នុងករណីនេះតតិយជនអាចដាក់ពាក្យបណ្ដឹងបានតាមរយៈសេចក្ដីចំរើនឥតហេតុ និងអាចទាមទារសំណងការខូចខាតតាមមាត្រា ៧៤៣ ហើយម្ចាស់បំណុលត្រូវក្លាយជាភាគីចុងចំម្លើយ។

## ២.៦. នីតិវិធីនៃ

### ២.៦.១. សមត្ថកិច្ច

ស្ថាប័នដែលមានសមត្ថកិច្ចដោះស្រាយបណ្ដឹងតវ៉ារបស់តតិយជន អាស្រ័យទៅតាមសមត្ថកិច្ចរបស់ស្ថាប័នអនុវត្តដោយបង្ខំ។[30]

ក្នុងករណីដែលតុលាការអនុវត្តមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំ តតិយជនដែលដាក់ពាក្យបណ្ដឹងតវ៉ាទៅនឹងការអនុវត្តដោយបង្ខំ ត្រូវដាក់ពាក្យបណ្ដឹងតវ៉ារបស់ខ្លួនទៅតុលាការអនុវត្ត។

សំណុំរឿងទាក់ទងនឹងពាក្យបណ្ដឹងតវ៉ារបស់តតិយជន គឺជាសំណុំរឿងមួយដាច់ដោយឡែកពីសំណុំរឿងអនុវត្តដោយបង្ខំ ប៉ុន្តែសំណុំរឿងនេះ ស្ថិតក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្ត

[២៩] មាត្រា៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៧។

[៣០] មាត្រា ៣៦៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ដែរ។ ក្នុងន័យនេះ សំណុំរឿងទាក់ទងនឹងបណ្តឹងតវ៉ារបស់តតិយជន និងត្រូវបែងចែកនៅស្ថាប័ននៃតុលាការអនុវត្ត ដោយយោងទៅតាមមាត្រា ២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ប្រសិនបើ អាជ្ញាសាលាមានសមត្ថកិច្ចក្នុងការអនុវត្តដោយបង្ខំ តតិយជនដែលដាក់ពាក្យបណ្តឹងតវ៉ាត្រូវដាក់ពាក្យបណ្តឹងរបស់ខ្លួនទៅសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។

### ២.៦.២ ការដាក់ពាក្យបណ្តឹង

ការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជន ត្រូវធ្វើឡើងដោយអនុលោមទៅតាមវិធីទូទៅសម្រាប់ការដាក់ពាក្យបណ្តឹង។ ចំពោះខ្លឹមសារនៃសាលក្រមដើមចោទទាមទារឲ្យតុលាការចេញត្រូវរៀបរាប់អំពីការសុំឲ្យចេញសាលក្រមខ្លឹមសារថា "ការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនេះត្រូវហាមឃាត់"។

លើសពីនេះទៅទៀត ក៏អាចទាមទារឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិរបស់បុគ្គលណាម្នាក់ផងដែរ។ ចំពោះមូលហេតុនៃការទាមទារ ត្រូវរៀបរាប់អំពីទំនាក់ទំនងគតិយុត្តជាសារធាតុ ដែលជាមូលហេតុនាំឲ្យការអនុវត្តបង្ខំនោះត្រូវហាមឃាត់។

### ២.៦.៣. ការផ្អាកការអនុវត្តដោយបង្ខំ ដោយបណ្តឹងតវ៉ារបស់តតិយជន

បណ្តឹងតវ៉ារបស់តតិយជន ពុំមានអានុភាពផ្អាកដោយស្វ័យប្រវត្តនូវការអនុវត្តដោយបង្ខំទេ ដោយសារបណ្តឹងតវ៉ាពុំមែនជានីតិវិធីបណ្តឹងឧបាស្រ័យ ហើយទោះបីជាវាជាប្រភេទមួយនៃឧបាស្រ័យក៏ដោយ ក៏វាជាឧបាស្រ័យពិសេសដែលត្រូវបានហាមឃាត់អានុភាពផ្អាករបស់វា។[31]

នៅក្នុងពាក្យបណ្តឹងតវ៉ារបស់តតិយជន តតិយជនអាចសុំឲ្យតុលាការនៃបណ្តឹងអង្គសេចក្តី (ពុំមែនស្ថាប័នអនុវត្តទេ) ផ្អាកជាបណ្តោះអាសន្ននូវការអនុវត្តដោយបង្ខំ ដោយធ្វើសេចក្តីបញ្ជាក់ដំបូង។ តុលាការអាចចេញដីកាសម្រេចមុនអង្គសេចក្តី បង្គាប់អោយផ្អាកជាបណ្តោះអាសន្នរហូតដល់សាលក្រមនៃបណ្តឹងតវ៉ារបស់តតិយជនបានប្រកាសដោយឲ្យ ឬមិនឲ្យដាក់ប្រាតិភោគបាន។

ដីកាសម្រេចខាងលើនេះ ក៏អាចត្រូវបានលុបចោលដោយម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំអោយតុលាការលុបចោល ហើយតុលាការអាចចេញដីកាសម្រេចលុបចោលការផ្អាកការអនុវត្តដោយបង្ខំ ដោយបង្គាប់ឲ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬមិនដាក់បាន។

[៣១] មាត្រា ៣៥១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នៅក្នុងសាលក្រមអង្គសេចក្ដីនៃបណ្ដឹងតវ៉ារបស់តតិយជនចំពោះការអនុវត្តដោយបង្ខំ តុលាការអាចសម្រេចលុបចោល ផ្លាស់ប្ដូរ ទទួលស្គាល់សេចក្ដីសម្រេចមុនអង្គសេចក្ដីរបស់ខ្លួន។

ការអនុវត្តដោយបង្ខំក៏អាចត្រូវបានផ្អាក ដោយពាក្យសុំដែលតតិយជនធ្វើឡើងចំពោះស្ថាប័នអនុវត្ត។ តុលាការអនុវត្ត ឬអាជ្ញាសាលា អាចចេញដីកាផ្អាកការអនុវត្តជាបណ្ដោះអាសន្នតាមពាក្យសុំរបស់តតិយជន ដោយធ្វើសេចក្ដីបញ្ជាក់ដំបូងអំពីហេតុដែលតវ៉ា និងស្ថានភាពបន្ទាន់នៃការផ្អាកនោះ។ ដីកាសម្រេចនេះ ត្រូវសរសេរពីការកំណត់រយៈពេលដើម្បីអោយតតិយជនដាក់សេចក្ដីចម្លងយថាភូតនៃដីកាសម្រេចផ្អាករបស់សាលាដំបូងនៃបណ្ដឹអង្គសេចក្ដីដូចបានរៀបរាប់ខាងលើ។

### ២.៦.៤. សាលក្រម ឬ សាលដីកា

បើតុលាការពិនិត្យឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ នោះតុលាការត្រូវចេញសាលក្រម ឬ សាលដីកាដែលប្រកាសថា "ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនេះត្រូវបានហាមឃាត់"។ នៅពេលសាលក្រម ឬ សាលដីកានេះចូលស្ថាពរ តតិយជនដែលជាដើមចោទនៃបណ្ដឹងតវ៉ារបស់តតិយជននោះ អាចទទួលបាននូវការផ្អាកការអនុវត្តដោយបង្ខំ ឬ ការលុបចោលនូវការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ហើយដាក់ឯកសារចម្លងយថាភូតនៃសាលក្រម ឬ សាលដីកានោះទៅស្ថាប័នអនុវត្ត[32]។ ប្រសិនបើការតវ៉ារបស់តតិយជន ពុំមានមូលហេតុត្រឹមត្រូវទេតុលាការត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលការទាមទារនោះ។

## ២.៧. ពន្ធដាក់ពាក្យបណ្ដឹង

ដូចជាបណ្ដឹងធម្មតាដែរ បទបញ្ញត្តិនៃគន្លឹះទី១ ទាក់ទងនឹងនឹងប្រាក់ប្រដាប់ក្ដីត្រូវយកមកអនុវត្តទៅលើពាក្យបណ្ដឹងតវ៉ារបស់តតិយជន។

ពេលដាក់ពាក្យបណ្ដឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់ដោយគណនាទៅតម្លៃនៃកម្មវត្ថុនៃបណ្ដឹងដែលបានកំណត់ក្នុងចំណុចនីមួយៗ។[33]

ការកំណត់អំពីតម្លៃកម្មវត្ថុនៃបណ្ដឹង នៅក្នុងបណ្ដឹងតវ៉ារបស់តតិយជន អាចជួបនឹងបញ្ហាខ្លះដែលត្រូវស្រាយបំភ្លឺឱ្យបានច្បាស់លាស់។ ជាទូទៅ តម្លៃកម្មវត្ថុនៃបណ្ដឹង គឺជាតម្លៃនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃពាក្យបណ្ដឹងតវ៉ារបស់តតិយជន។ ប៉ុន្តែប្រសិនបើ តម្លៃនៃទ្រព្យសម្បត្តិ

[៣២] មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧។

[៣៣] មាត្រា ៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

ដែលជាកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ារបស់តតិយជន មានតម្លៃច្រើនជាងសិទ្ធិលើបំណុល តម្លៃកម្មវត្ថុនៃបណ្តឹងគឺជាតម្លៃនៃសិទ្ធិលើបំណុល។

ឧទាហរណ៍: ប្រសិនបើ ម្ចាស់បំណុលនៃការអនុវត្ត មានសិទ្ធិទាមទារប្រាក់ចំនួន៣០ លានរៀល ពីកូនបំណុលនៃការអនុវត្តតាមអំណាចសាលក្រម ហើយម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅលើដីមួយកន្លែងដែលមានតម្លៃ ២០ លានរៀល ប៉ុន្តែតតិយជនបានអះអាងថា ដីនោះជាកម្មសិទ្ធិរបស់ខ្លួន ហើយបានដាក់ពាក្យបណ្តឹងតវ៉ា។ ក្នុងករណីនេះ តម្លៃ ២០ លានរៀល គឺជាផលប្រយោជន៍អតិបរមាដែលតតិយជនអាចទទួលបានពីការដាក់ពាក្យបណ្តឹងរបស់ខ្លួន។

ហេតុនេះ តម្លៃកម្មវត្ថុនៃបណ្តឹងតវ៉ារបស់តតិយជន គឺ ២០លានរៀល ពីព្រោះគោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺគ្រាន់តែបញ្ឈប់នូវការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិជាក់លាក់ណាមួយតែប៉ុណ្ណោះ។

ផ្ទុយទៅវិញ ប្រសិនបើដីដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំមានតម្លៃ ៥០ លានរៀលវិញ នោះផលប្រយោជន៍នៃការដាក់ពាក្យបណ្តឹងតវ៉ារបស់តតិយជនមានតម្លៃត្រឹមតែ ៣០លានតែប៉ុណ្ណោះ ដែលជាតម្លៃនៃសិទ្ធិលើបំណុលទាមទារដោយម្ចាស់បំណុលនៃការអនុវត្ត ពីព្រោះអ្វីដែលត្រូវបានបំពាននោះគឺគ្រាន់តែតម្លៃមួយផ្នែកនៃ ៣០ លានរៀល នៃតម្លៃកម្មវត្ថុតែប៉ុណ្ណោះ។

## ២.៨. ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ

គោលបំណងនៃបណ្តឹងតវ៉ារបស់តតិយជន គឺទាមទារកុំឱ្យអនុញ្ញាតការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ដោយហេតុថា តតិយជនមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះដល់ការធ្វើអនុប្បទាន ឬប្រគល់។[34]

នៅក្នុងការសរសេរពាក្យបណ្តឹងតវ៉ារបស់តតិយជន ដើមចោទត្រូវគោរពតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយយោងតាមមាត្រា ៣៣៥ នៃក្រមដែលឱ្យយកបញ្ញត្តិពីគន្លឹទី២ ដល់គន្លឹទី៤ នៃក្រមនេះយកមកអនុវត្តដូចគ្នាចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ។

[៣៤] មាត្រា ៣៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងន័យនេះ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញគឺ "ការអនុវត្តដោយបង្ខំដោយចុងចំលើយចំពោះអចលនវត្ថុដែលពិណ៌នានៅក្នុងបញ្ជីអចលនវត្ថុ ដោយផ្អែកលើសាលក្រមចុងក្រោយ មិនត្រូវបានអនុញ្ញាត"។

ក្នុងករណីដែលតុលាការយល់ឃើញថា ការអនុវត្តដោយបង្ខំនឹងបំពានដល់កម្មសិទ្ធិ ឬសិទ្ធិរបស់តតិយជន តុលាការនឹងចេញសាលក្រមដែលមានខ្លឹមសារដូចរៀបរាប់ខាងលើ។ ជាចុងបញ្ចប់ ការអនុវត្តដោយបង្ខំទៅលើវត្ថុដែលមានពាក់ព័ន្ធនឹងសិទ្ធិរបស់តតិយជន នឹងមិនអាចធ្វើទៅបាន គឺមានន័យថាសិទ្ធិរបស់តតិយជនជាដើមចោទនៅក្នុងបណ្តឹងតវ៉ានោះនឹងត្រូវបានធានាការពារ។

ពេលខ្លះ សេចក្តីសំរេចរបស់តុលាការទៅលើបណ្តឹងតវ៉ារបស់តតិយជន ពុំមានផលប៉ះពាល់ណាមួយដល់លិខិតអនុវត្តទេ ប៉ុន្តែពេលខ្លះការសម្រេចមិនអនុញ្ញាតការអនុវត្តដោយបង្ខំអាចមានផលប៉ះពាល់ដល់លិខិតអនុវត្តទាំងមូលបាន។

# ជំពូកទី៣
# ចំណាត់ការលើបណ្តឹងតវ៉ា
# របស់តតិយជន

# ជំពូកទី៣

# ចំណាត់ការលើបណ្ដឹងតវ៉ារបស់តតិយជន

បណ្ដឹងតវ៉ារបស់តតិយជន ជាបណ្ដឹងរបស់តតិយជនដែលមានកម្មសិទ្ធ ជាអាទិ៍ ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ទាមទារកុំឱ្យអនុញ្ញាតការអនុវត្តទៅលើទ្រព្យសម្បត្តិជាក់លាក់ដោយផ្អែកលើលិខិតជាក់លាក់ ចំពោះម្ចាស់បំណុលនៃការអនុវត្ត។

បណ្ដឹងតវ៉ារបស់តតិយជន គឺធ្វើឡើងតាមនីតិវិធីរដ្ឋប្បវេណីទូទៅ។ ដូចនេះ ការវិនិច្ឆ័យលើបណ្ដឹងនេះត្រូវយកក្រមនីតិវិធីរដ្ឋប្បវេណីគន្ថីទី២ និងគន្ថីទី៣ មកអនុវត្ត ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ និងការទាញហេតុផលផ្ទាល់មាត់ គឺត្រូវតែមានជាចាំបាច់។

បណ្ដឹងតវ៉ានេះ អាចដាក់បានមិនត្រឹមតែករណីការអនុវត្តដោយបង្ខំក្នុងន័យចង្អៀតនោះទេ ការអនុវត្តសិទ្ធិប្រាតិភោគ និងការអនុវត្តរក្សាការពារក៏អាចដាក់បានដែរ។

## ៣.១. ការរៀបចំពាក្យបណ្ដឹង

### ៣.១.១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

#### ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ

អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ សំដៅលើអង្គហេតុដែលបញ្ជាក់ពីខ្លឹមសារនៃសិទ្ធិលើបំណុលដែលទាមទារ ហើយអង្គហេតុនេះ ត្រូវតែសរសេរបញ្ជាក់ឱ្យច្បាស់លាស់នៅក្នុងពាក្យបណ្ដឹង។ ហេតុនេះ ដើមចោទត្រូវសរសេរបញ្ជាក់អំពីអត្តសញ្ញាណរបស់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ ប៉ុន្តែ ជាក់ស្ដែងអង្គហេតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ហើយវាមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើការបញ្ជាក់។

#### គ..អង្គហេតុដែលជាមូលហេតុនៃការទាមទារ

អង្គហេតុដែលជាមូលហេតុនៃការទាមទារ សំដៅលើអង្គហេតុដែលបង្កើតនូវសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ។ នៅក្នុងពាក្យបណ្ដឹងរបស់ដើមចោទ គប្បីសរសេរបញ្ជាក់អំពីអង្គហេតុដែលបង្ហាញឱ្យឃើញអំពីការចាប់ផ្ដើមអនុវត្តដែរ លើកលែងតែករណីដែលលិខិតអនុវត្តមានខ្លឹមសារជាការប្រគល់នូវវត្ថុជាក់លាក់ណាមួយ។

## ៣.២. សមត្ថកិច្ចសាលាជម្រះក្ដី

ក្នុងករណីតុលាការជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ នាំឲ្យតុលាការនោះជាអ្នកអនុវត្ត។ ក្នុងករណីអាជ្ញាសាលាជាស្ថាប័នដែលត្រូវអនុវត្តដោយបង្ខំ នាំឲ្យសាលាដំបូងដែលជាអាជ្ញាសាលានោះស្ថិតនៅ គឺជាសមត្ថកិច្ច។

នៅក្នុងប្រទេសជប៉ុន ប្រសិនបើសាលាឧទ្ធរណ៍ជាតុលាការអនុវត្តសាលាដំបូងមានសិទ្ធិជាសមត្ថកិច្ចជម្រះក្ដីលើកទីមួយចំពោះការតវ៉ារបស់តតិយជន ការអនុវត្តបែបនេះធ្វើឡើងដោយពិចារណាអំពីផលប្រយោជន៍នៃការការទទួលបានការជម្រះក្ដីគ្រប់ថ្នាក់របស់ភាគី និងការទទួលបន្ទុកតាមមុខងាររបស់តុលាការ។

## ៣.៣. ពេលដាក់ពាក្យបណ្ដឹង

កម្មវត្ថុការអនុវត្តមិនអាចកំណត់បានទេ បើសិនមិនមែននៅក្រោយពេលចាប់ផ្ដើមអនុវត្ត។ ក្នុងករណីកម្មវត្ថុនៃការអនុវត្តអាចកំណត់បាននៅដំណាក់កាលលិខិតអនុវត្ត (ការអនុវត្តដោយបង្ខំនៃសិទ្ធិទាមទារឱ្យប្រគល់ ឬការប្រគល់វត្ថុជាក់លាក់) យើងអាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបាននៅមុនពេលចាប់ផ្ដើមការអនុវត្តដោយបង្ខំ។

បណ្ដឹងតវ៉ារបស់តតិយជនមិនអាចដាក់បានក្រោយពេលបញ្ចប់នៃការអនុវត្តដោយបង្ខំទេ។

## ៣.៤. ការរួមបញ្ចូលបណ្ដឹង

បណ្ដឹងតវ៉ារបស់តតិយជនជាបណ្ដឹងរដ្ឋប្បវេណី ហេតុដូច្នេះ បណ្ដឹងនេះអាចរួមបញ្ចូលជាមួយបណ្ដឹងផ្សេងបាន។

ប្រភេទនៃបណ្ដឹងដែលមានលក្ខណៈសមស្របដើម្បីបញ្ចូលបានមានដូចជា បណ្ដឹងទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនៃការអនុវត្តដែលតតិយជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ឬការទាមទារសំណងការខូចខាត (អំពើអនីត្យានុកូល) ដោយផ្អែកលើការអនុវត្តដោយបង្ខំដែលមិនត្រឹមត្រូវដែលតតិយជនបានដាក់ចំពោះម្ចាស់បំណុលនៃការអនុវត្តជាអាទិ៍។

## ៣.៥. ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងរដ្ឋប្បវេណី ហេតុនេះ យើងអាចផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងបាន ប្រសិនបើលក្ខខណ្ឌបានបំពេញ។

ឧទាហរណ៍: ចំពោះការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង យើងអាចពិចារណាបានក្នុងករណីដែលការអនុវត្តបានបញ្ចប់នៅពេលដែលបណ្តឹងតវ៉ារបស់តតិយជនកំពុងតែដំណើរការ នោះបណ្តឹងតវ៉ារបស់តតិយជននឹងក្លាយជាខុសច្បាប់ ហេតុនេះដើមចោទអាចដាក់ពាក្យសុំផ្លាស់ប្តូរកម្មវត្ថុបណ្តឹងទៅជាការទាមទារសំណងការខូចខាត បើសិនជាដើមចោទទទួលរងការខូចខាតដោយសារតែការអនុវត្តនោះ។

## ៣.៦. ការវិនិច្ឆ័យបណ្តឹងតវ៉ារបស់តតិយជន

បណ្តឹងតវ៉ារបស់តតិយជននឹងត្រូវបានទទួលស្គាល់ ក្នុងករណីដែលៈ

១. តតិយជន (ដើមចោទ) មានសិទ្ធិជាក់លាក់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត

២. ហើយសិទ្ធិនោះត្រូវទទួលយកការអនុវត្តដែលបំពាននោះ។

៣. តតិយជននោះមិនមានមូលហេតុនឹងត្រូវទទួលយកការអនុវត្តដែលបំពាននោះ។

តតិយជន (ដើមចោទ) ត្រូវតែអះអាងអំពីសិទ្ធិលើកម្មវត្ថុនៃការអនុវត្ត អំពីការទទួលរងការបំពានខុសច្បាប់សារធាតុនៅក្នុងទំនាក់ទំនងជាមួយម្ចាស់បំណុលនៃការអនុវត្ត(ចុងចម្លើយ)។

ចំណុចសំខាន់ដើម្បីសម្រេចថាទទួលស្គាល់ ឬមិនទទួលស្គាល់បណ្តឹងតវ៉ារបស់តតិយជនមាន២ ចំណុចដូចខាងក្រោមៈ

១. តើដើមចោទមានសិទ្ធិដែលអាចតតាំងជាមួយម្ចាស់បំណុលនៃការអនុវត្ត (សិទ្ធិដែលអាចរាំងស្ទះការធ្វើអនុប្បទានឬប្រគល់វត្ថុដែលជាកម្មវត្ថុ)ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដែរ ឬទេ?

២. តើសិទ្ធិខាងលើរបស់ដើមចោទត្រូវបានបំពានដោយការអនុវត្តដែរឬទេ?

## ៣.៧. អង្គហេតុចម្បង

អង្គហេតុចម្បងនៃការតវ៉ារបស់របស់តតិយជនគឺៈ

**ក. អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

១. ការចាប់ផ្តើមនីតិវិធីអនុវត្តជាក់ស្តែង (ករណីទូទៅ)

២. អង្គហេតុដែលជាមូលហេតុនៃការកកើតសិទ្ធិដែលវាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់វត្ថុដែលជាកម្មវត្ថុ

ខ. ការតវ៉ា

៣. ការបញ្ចប់នីតិវិធីអនុវត្ត

៤. អង្គហេតុរំលត់សិទ្ធិ ឬឧបសគ្គនៃការកកើតសិទ្ធិដែលវាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់របស់ដើមចោទ។

## ៣.៨. ហេតុនៃការតវ៉ា

### ៣.៨.១. កម្មសិទ្ធិ

បុគ្គលដែលមានកម្មសិទ្ធិចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ អាចដាក់បណ្តឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តលើកម្មវត្ថុខាងលើ។

លើកលែងករណីកម្មសិទ្ធិកម្មសិទ្ធិនោះអាចតតាំងចំពោះម្ចាស់បំណុល (ចុងចម្លើយ) បាន។ អនុវត្តដូចគ្នាចំពោះសិទ្ធិប្រត្យក្សផ្សេងទៀត។

ធម្មតាបើសិនជាការអនុវត្តដោយបង្ខំនោះ មិនធ្វើឱ្យបំពានដល់កម្មសិទ្ធិទេ បណ្តឹងតវ៉ារបស់តតិយជនដែលធ្វើឡើងដោយកម្មសិទ្ធិករមិនត្រូវបានទទួលស្គាល់ទេ។

### ៣.៨.២. សិទ្ធិកាន់កាប់

អ្នកមានសិទ្ធិកាន់កាប់ដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី អាចដាក់បណ្តឹងតវ៉ារបស់តតិយជន បើសិនជាសិទ្ធិកាន់កាប់ត្រូវបានបំពានដោយការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តចំពោះអ្នកដទៃ។

### ៣.៨.៣. សិទ្ធិជួលអចិន្ត្រៃយ៍ និងសិទ្ធិផលុបភោគ ជាអាទិ៍

ជាគោលការណ៍ ការអនុវត្តដោយបង្ខំចំពោះកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍អាទិ៍ គឺមិនបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះទេ ហេតុនេះ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍មិនអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបានឡើយ។ ប៉ុន្តែ ជាករណីលើកលែង ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ជាអាទិ៍ អាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន បើសិនការអនុវត្តដោយបង្ខំលើកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ជាដើម ដោយផ្អែកតាមលិខិត អនុវត្តចំពោះអ្នកដទៃ ធ្វើឱ្យបំពានដល់សិទ្ធិជួលអចិន្ត្រៃយ៍ទាំងនោះ។

### ៣.៨.៤. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ជាគោលការណ៍ យើងអាចពិចារណាដូចគ្នានឹងកម្មសិទ្ធិករ។ មានន័យថា អ្នកដែលមានសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត អាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបាន ក្នុងករណីសិទ្ធិទាំងនោះត្រូវបានបំពាន ដោយសារការអនុវត្តដោយបង្ខំផ្អែកតាមលិខិតអនុវត្តរបស់អ្នកដទៃ។

### ៣.៨.៥. សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិ

ម្ចាស់សិទ្ធិហ៊ីប៉ូតែក និងឯកសិទ្ធិមានសិទ្ធិទទួលបានការសងដោយអាទិភាពពីវត្ថុដែលជាកម្មវត្ថុ ហេតុនេះ ជាគោលការណ៍ម្ចាស់សិទ្ធិហ៊ីប៉ូតែក ជាអាទិ៍មិនអាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបានទេ ពីព្រោះសិទ្ធិហ៊ីប៉ូតែក ជាអាទិ៍ មិនត្រូវបានបំពានដោយការអនុវត្តដោយបង្ខំចំពោះវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិហ៊ីប៉ូតែកនោះទេ។

ប៉ុន្តែ នៅពេលដែលការអនុវត្តត្រូវបានធ្វើឡើងតែមួយផ្នែក និងបំបែកវត្ថុដែលជាកម្មវត្ថុនោះ ហើយកម្មវត្ថុនោះនៅមានតម្លៃជាប្រាតិភោគនៅពេលមិនបំបែកប៉ុណ្ណោះ។ ឧទាហរណ៍: ម្ចាស់បំណុលទូទៅបានរឹបអូសដើមឈើដែលអានុភាពនៃសិទ្ធិហ៊ីប៉ូតែកខាងលើ ករណីនេះ ម្ចាស់សិទ្ធិហ៊ីប៉ូតែកអាចដាក់បណ្ដឹងតវ៉ារបស់តតិយជន និងដកចេញការអនុវត្តលើដើមឈើនោះបាន ដោយសារតែម្ចាស់សិទ្ធិហ៊ីប៉ូតែកមិនមានករណីយកិច្ចទទួលយកការធ្លាក់តម្លៃលើវត្ថុដែលជាកម្មវត្ថុប្រាតិភោគទេ។

### ៣.៨.៦. សិទ្ធិឃាត់ទុក

ករណីកម្មវត្ថុគឺជាអចលនវត្ថុ ជាគោលការណ៍ ការអនុវត្តដោយបង្ខំមិនធ្វើឱ្យបំពានសិទ្ធិឃាត់ទុកទេ ហេតុនេះ ម្ចាស់សិទ្ធិឃាត់ទុកមិនអាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបានទេ។

ប៉ុន្តែ ម្ចាស់សិទ្ធិឃាត់ទុកអាចដាក់បណ្ដឹងតវ៉ារបស់តតិយជនបាន នៅក្នុងករណីការអនុវត្តដោយបង្ខំទាមទារឱ្យប្រគល់ ឬករណីរឹបអូសលើចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិឃាត់ទុកដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិឃាត់ទុកបាន។

### ៣.៨.៧. ប្រាតិភោគដោយអនុប្បទាន

នៅក្នុងប្រាតិភោគដោយអនុប្បទាន កម្មសិទ្ធិត្រូវផ្ទេរទៅឱ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ហេតុនេះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចដាក់បណ្តឹងតវ៉ារបស់តតិយជនបាន ក្នុងករណីម្ចាស់បំណុលរបស់អ្នកបង្កើតបានអនុវត្តដោយបង្ខំលើវត្ថុដែលជាកម្មវត្ថុ។

### ៣.៨.៨. ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់

មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុចុះថ្ងៃទី........... ខែ........... ឆ្នាំ.......... តាមសេចក្តីចម្លងយថាភូតនៃសាលក្រមដែលបានផ្តល់រូបមន្តអនុវត្តក្នុងរឿងក្តី (ឈ្មោះតុលាការ លេខរឿងក្តី និងឈ្មោះរឿងក្តី) របស់ចុងចម្លើយ (ឈ្មោះកូនបំណុល)។

## ៣.៩. អាជ្ញាអស់ជំនុំ

បណ្តឹងតវ៉ារបស់តតិយជនជានីតិវិធីនៃបណ្តឹង ហេតុនេះ អានុភាពនៃអាជ្ញាអស់ជំនុំកើតមានចំពោះអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិតវ៉ា។[35]

នៅក្នុងករណីដែលបណ្តឹងតវ៉ារបស់តតិយជនត្រូវបានច្រានចោល ដើមចោទមិនអាចទាមទារឱ្យសងនូវសេចក្តីចម្រើនឥតហេតុដោយមូលហេតុការអនុវត្តនោះខុសច្បាប់ ឬមិនត្រឹមត្រូវ និង មិនអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលទេ។

## ៣.១០. នីតិវិធីក្រោយចេញសាលក្រម

ទោះបីជាមានសាលក្រមទទួលស្គាល់ការតវ៉ារបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនត្រូវបានផ្អាក (លុបចោល) ដោយឯកឯងនោះទេ។ យើងត្រូវដាក់សេចក្តីចម្លងយថាភូតនៃសាលក្រមទៅទុលការអនុវត្ត ឬអាជ្ញាសាលា ដើម្បីផ្អាកការអនុវត្ត (លុបចោល)។

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមិនមានបញ្ញត្តិថាត្រូវ ឬមិនត្រូវរង់ចាំការចូលជាស្ថាពរនៃសាលក្រមតវ៉ារបស់តតិយជន ដើម្បីផ្អាកការអនុវត្តដោយបង្ខំនោះទេ (លុបចោល)។

[៣៥] មាត្រា ១៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ប៉ុន្តែ យើងខ្ញុំយល់ថាសេចក្តីសម្រេចនោះគួរតែចូលជាស្ថាពរសិន ដើម្បីក្លាយជាលិខិតដែលមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ខ ដោយផ្អែកតាមហេតុផលខាងក្រោមៈ

- ក្នុងករណីដើមចោទឈ្នះក្តីក្នុងការតវ៉ារបស់តតិយជន តុលាការអាចសម្រេចសេចក្តីអំពីការតវ៉ារបស់តតិយជនជាមួយនឹងការសម្រេចសេចក្តីអំពីការផ្អាកការអនុវត្ត ឬការផ្អាក ការលុបចោលការអនុវត្តបាន
- អានុភាពអនុវត្ត នៃសាលក្រមកើតឡើងពេលចូលជាស្ថាពរ
- ប្រសិនបើអាចលុបចោលការអនុវត្តដោយបង្ខំនៅក្នុងស្ថានភាពមុនពេលស្ថាពរបាន ម្ចាស់បំណុលនឹងទទួលការខូចខាតយ៉ាងខ្លាំង នៅពេលដែលលទ្ធផលប្រែប្រួលនៅតុលាការជាន់ខ្ពស់។

## ៣.១១. ការសះជា

បណ្តឹងតវ៉ារបស់តតិយជនជាបណ្តឹងធម្មតា ហេតុនេះការសះជាក៏ធ្វើបានដែរ។ ជាធម្មតាយើងមិនមែនសះជាអំពីខ្លឹមសារនៃសិទ្ធិតវ៉ានោះទេ (មិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ ជាអាទិ៍) ប៉ុន្តែយើងបញ្ចូលខ្លឹមសារ និងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិតាមច្បាប់សារធាតុដែលជាមូលហេតុនៃការតវ៉ា (ការបញ្ជាក់អំពីកម្មសិទ្ធិ ជាអាទិ៍) ទៅក្នុងចំណុចសះជា។ លើសពីនេះ យើងក៏មានបញ្ចូលចំណុចដូចជា មិនអនុវត្តដោយបង្ខំផងដែរ។ នៅក្នុងករណីណាក៏ដោយ យើងត្រូវធ្វើយ៉ាងណាមិនឱ្យនៅសល់សិទ្ធិតវ៉ាតាមនីតិវិធីច្បាប់ ហើយជាទូទៅយើងកំណត់ទុកជាមុនអំពីការព្រមព្រៀងបញ្ចប់បណ្តឹង ឬព្រមព្រៀងដកបណ្តឹងតវ៉ានោះ។

## ៣.១២. ការផ្អាកការអនុវត្ត

ទោះបីជាដាក់បណ្តឹងរបស់តតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំមិនផ្អាកដោយឯកឯងដែរ។ ដើម្បីផ្អាកការអនុវត្តដោយបង្ខំ យើងត្រូវដាក់ពាក្យសុំផ្អាកការអនុវត្តទៅតុលាការដែលបានទទួលពាក្យបណ្តឹង។[36]

[៣៦] មាត្រា ៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៣.១២.១. លំហូរនៃការផ្អាកការអនុវត្ត

**<u>តារាងទី១</u>** តារាងលំហូរនៃការផ្អាកការអនុវត្ត

| |
|---|
| **បណ្តឹងតវ៉ារបស់តតិយជន** |
| ↓ |
| **ពាក្យសុំផ្អាកការអនុវត្ត** |
| ↓ |
| **វិនិច្ឆ័យការផ្អាកការអនុវត្ត** |
| ↓ |
| **ដីការកំណត់តម្លៃប្រាតិភោគ និងការដាក់ប្រាតិភោគ** |
| ↓ |
| **ដីកាសម្រេចផ្អាកការអនុវត្ត** |
| ↓ |
| **ដាក់សេចក្តីចម្លងយថាភូតនៃដីកាសម្រេចទៅតុលាការអនុវត្តជាអាទិ៍** |
| ↓ |
| **ការអនុវត្តដោយបង្ខំត្រូវបានផ្អាកមួយរយៈ** |

<u>ប្រភព</u> សារសិក្ខាសាលាធ្វើឡើងដោយគម្រោង JICA ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៨

### ៣.១២.២. ពាក្យសុំផ្អាកការអនុវត្ត

ក. សមត្ថកិច្ច គឺតុលាការដែលទទួលពាក្យបណ្តឹងតវ៉ារបស់តតិយជន។

ខ. ខ្លឹមសារនៃពាក្យសុំផ្អាក

- ការអនុវត្តដោយបង្ខំមួយរយៈ
- ផ្អាកការអនុវត្តដោយបង្ខំមួយរយៈ
- លុបចោលការចាត់ចែងការអនុវត្តដែល បាន ធ្វើរួចហើយ

ការផ្អាកការអនុវត្តមួយរយៈ គឺជាអំឡុងពេលដែលត្រូវសម្រេចសេចក្តីលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់លើសាលក្រមចុងក្រោយ នៅក្នុងដីកាសម្រេចផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។

### ៣.១២.៣. លក្ខខណ្ឌនៃការផ្អាកការអនុវត្ត

មានការដាក់បណ្តឹងតវ៉ារបស់តតិយជន និង មានការបញ្ជាក់ដំបូងអំពីហេតុនៃការតវ៉ាដែលបានអះអាង។

គឺជាការបញ្ជាក់ដំបូងអំពីអត្ថិភាពនៃ កម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលអាចរាំងស្ទះការធ្វើអនុប្បទាន ឬការប្រគល់វត្ថុដែលជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំ។

### ៣.១២.៤. វិធីវិនិច្ឆ័យ

ជាទៅទៅការវិនិច្ឆ័យធ្វើឡើងទៅលើតែឯកសារ ដោយមិនមានការបើកការទាញហេតុផលផ្ទាល់មាត់ ឬសាកសួរភាគីម្ខាងទៀតទេ។

ក. មានភាពប្រញាប់។

ខ. នៅក្នុងសាលក្រមចុងក្រោយ តុលាការមានឆន្ទានុសិទ្ធិសម្រេចអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់សេចក្តីសម្រេចផ្អាកការអនុវត្តជាអាទិ៍ ហេតុនេះ ទោះបីជាមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬសាកសួរភាគីម្ខាងទៀតក៏ដោយក៏តុលាការអាចស្តាប់យោបល់របស់ភាគីម្ខាងទៀតបាននៅក្នុងបណ្តឹងអង្គសេចក្តីដែរ។

### ៣.១២.៥. អំពីប្រាតិភោគ

#### ក. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ

តុលាការអាចបង្គាប់ឱ្យដាក់ ឬមិនដាក់ប្រាតិភោគបាន។ ប្រសិនបើត្រូវដាក់ប្រាតិភោគក៏ដោយក៏ប្រាតិភោគនោះធ្វើឡើងសម្រាប់តែការខូចខាតដែលកើតមានចំពោះម្ចាស់បំណុល ដោយសារយឺតយ៉ាវនៃការអនុវត្តនោះទេ ហេតុនេះតម្លៃប្រាតិភោគជាទូទៅមិនមានចំនួនច្រើនខ្លាំងទេ។

#### ខ. ការផ្អាកការអនុវត្តដោយបង្ខំមួយរយៈ រួមទាំងលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ។

តុលាការត្រូវតែបង្គាប់ឱ្យដាក់ប្រាតិភោគ តម្លៃប្រាតិភោគ គឺតម្រូវឱ្យគ្រប់ចំនួនការពារផលប្រយោជន៍ទាំងអស់ដែលម្ចាស់បំណុលមានលើការអនុវត្តចាត់ចែងដែលត្រូវបានលុបចោល ហេតុនេះតម្លៃប្រាតិភោគមានចំនួនច្រើនខ្លាំង។

ក្នុងករណីតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគ ដំបូងតុលាការនឹងចេញដីកាសម្រេចអំពីតម្លៃប្រាតិភោគ (ឬវត្ថុដែលជាប្រាតិភោគ) និងអំឡុងពេលដាក់ប្រាតិភោគ។ តុលាការចេញដីកាផ្អាកការអនុវត្ត ក្រោយពីបញ្ជាក់ថាបានដាក់ប្រាតិភោគ។

វិធីដាក់ប្រាតិភោគគឺតម្កល់ ឬផ្ញើប្រាក់ជាអាទ៍ នៅទីកន្លែងតម្កល់ (តុលាការ)។

ក្នុងករណីដែលមិនបានដាក់ប្រាតិភោគក្នុងអំឡុងពេលកំណត់ទេ តុលាការនឹងលើកចោលពាក្យសុំ។

### ៣.១២.៦. ខ្លឹមសារនៃដីកាសម្រេច

ករណីតុលាការបានចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ តុលាកានឹងចេញដីកាសម្រេចអំពីការផ្អាកការអនុវត្តក្រោយពេលបញ្ជាក់អំពីការដាក់ប្រាតិភោគ។

- តុលាការអាចបង្គាប់ឱ្យដាក់ ឬមិនដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្នបាន។
- តុលាការត្រូវបង្គាប់ឱ្យដាក់ប្រាតិភោគសម្រាប់ការផ្អាកការអនុវត្តដោយបង្ខំជាបណ្តោះអាសន្នរួមទាំងលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយ។

តុលាការមានឆន្ទានុសិទ្ធិក្នុងការចេញដីកាសម្រេចណាមួយ។ ប៉ុន្តែ តុលាការមិនអាចចេញដីកាសម្រេចលុបចោលការអនុវត្តចំពោះពាក្យសុំដែលទាមទារត្រឹមតែការផ្អាកការអនុវត្តនោះទេ។

### ៣.១២.៧. ដីកាសម្រេចផ្អាកការអនុវត្តដោយខ្ញុំ

អ្នកដាក់ពាក្យសុំបានដាក់បណ្តឹងតវ៉ារបស់តតិយជនចំពោះការអនុវត្តដោយបង្ខំផ្អែកតាមសេចក្តីចម្លងយថាភូតនៃសាលក្រមដែលមានអនុភាពអនុវត្តចំពោះ (រឿងក្តីឈ្មោះ....រឿងក្តីលេខ.... និងតុលាការ...) ពីភាគីម្ខាងទៀត (កូនបំណុលឈ្មោះ....) និងបានដាក់ពាក្យសុំផ្អាកការអនុវត្តនោះ។ តុលាការទទួលស្គាល់ថាពាក្យសុំនោះមានមូលហេតុសមរម្យ ហើយអ្នកដាក់ពាក្យសុំបានដាក់តម្កល់ជាប្រាក់ប្រាតិភោគចំនួន....។

### ៣.១២.៨. សេចក្តីសម្រេចបញ្ចប់

ផ្អាកការអនុវត្តដោយបង្ខំមួយរយៈលើវត្ថុដូចមានក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុចុះថ្ងៃទី...... ខែ..........ឆ្នាំ......... (សង្ខេប) ផ្អែកតាមការអនុវត្តខាងលើ រហូតដល់តុលាការនៃបណ្តឹងអង្គសេចក្តី ធ្វើការសម្រេចអំពីការលុបចោល ឬផ្លាស់ប្តូរ ឬទទួលស្គាល់ការអនុវត្ត។

#### ក. ក្រោយចេញដីកាសម្រេច

ការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាក (ត្រូវបានលុបចោល) បើសិនជាភាគីបានដាក់សេចក្តីចម្លងយថាភូតនៃដីកាសម្រេចផ្អាកការអនុវត្ត (លុបចោល) ទៅតុលាការអនុវត្ត ឬអាជ្ញាសាលា។

#### ខ. ការធ្វើឧបាស្រ័យ

ភាគីមិនអាចធ្វើឧបាស្រ័យចំពោះដីកាសម្រេចផ្អាកការអនុវត្ត (របស់តុលាការនៃបណ្តឹងតវ៉ារបស់តតិយជន) ដោយសារតែមិនមានបញ្ញត្តិទទួលស្គាល់ការប្តឹងជំទាស់។ ប៉ុន្តែ ភាគីអាចដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត (របស់តុលាការអនុវត្ត) ក្នុងករណីដែលការអនុវត្តដោយបង្ខំត្រូវបានផ្អាកដែលផ្អែកលើសេចក្តីចម្លងយថាភូតនៃដីកាសម្រេចនេះបាន។

#### គ. ឋានៈរបស់ដីកាសម្រេចផ្អាកការអនុវត្តនៅក្នុងសាលក្រមចុងក្រោយ

តុលាការអាចធ្វើការផ្អាកការអនុវត្ត ឬផ្អាកការអនុវត្ត និង លុបចោលការចាត់ចែង នៅក្នុងសាលក្រមចុងក្រោយនៃការតវ៉ារបស់តតិយជនបាន។ ប្រសិនបើសេចក្តីសម្រេចអំពីការផ្អាកការអនុវត្តជាដើមត្រូវបានផ្អាកហើយ តុលាការត្រូវតែសម្រេចថាលុបចោលផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចទាំងនោះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

## ១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងចងក្រងអត្ថបទសារណាលើប្រធានបទ "បណ្តឹងតវ៉ារបស់តតិយជន" នេះមក យើងយល់ឃើញថា ការវិវត្តរបបគតិយុត្តរបស់បណ្តឹងតវ៉ា គឺផ្អែកលើការប្រែប្រួលនូវព្រឹត្តិការណ៍សង្គមពីសម័យកាលមួយទៅសម័យកាលមួយ។ ការវិវត្តនេះបានធ្វើឱ្យប្រទេសកម្ពុជារំកិលខ្លួនទៅជាប្រទេសមួយដែលមាននីតិរដ្ឋពេញលេញ។ ដោយសារតែ ត្រូវកាសង្គមជាកត្តាចម្បង និង ចាំបាច់បានបណ្តាឱ្យមានប្រភពនៃការវិវត្តបណ្តឹងតវ៉ារបស់តតិយជន គឺផុសចេញពីអំណាចនីតិប្រតិបត្តិ។

យើងអាចសន្និដ្ឋានបានថា នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានគោរពនូវគោលការចំពោះមុខ និងសិទ្ធិក្នុងការពឹងពាក់តុលាការក្នុការដោះស្រាយវិវាទរដ្ឋប្បវេណី។ ស្របទៅនឹងគោលការណ៍ចំពោះមុខ និងសិទ្ធិក្នុងការពឹងពាក់តុលាការក្នុងការដោះស្រាយ វិវាទរដ្ឋប្បវេណីទើបក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិស្តីពី បណ្តឹងតវ៉ារបស់តតិយជន ដែលអាចធ្វើប្រឆាំងទៅនឹងការអនុវត្តដោយបង្ខំ ហើយបើសិទ្ធិដល់ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមឲ្យអនុវត្តដោយបង្ខំ ឬផ្សេងទៀត មានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិទាមទារឱ្យ តុលាការ ឬចៅក្រមដែលបានចេញសាលក្រមនោះធ្វើការសម្រេចសេចក្តីម្តងទៀត ឬ ឈានដល់ការលុបចោលតែម្តង។

បទបញ្ញត្តិពាក់ព័ន្ធនឹងបណ្តឹងតវ៉ារបស់តតិយជន ដែលមានចែងនៅ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ គឺមានភាពល្អប្រសើរ និងជាកត្តាមួយដ៏សំខាន់ក្នុងការរួមចំណែកស្វែងរកយុត្តិធម៌ជូនភាគី និងបានផ្តល់នូវសិទ្ធិដល់តតិយជន មានសិទ្ធិក្នុងការធ្វើបណ្តឹងតវ៉ាដើម្បីបង្ហាញនូវសិទ្ធិ និងដាក់មធ្យោបាយក្នុងការតទស់ឱ្យអស់ពីលទ្ធភាព។ នៅពេលដែលគូភាគីបានប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនរួចហើយ និងព្រមទទួលយកនូវសេចក្តីសម្រេចរបស់តុលាការ។

សរុបមក យើងអាចនិយាយបានថា បណ្តឹងតវ៉ារបស់តតិយជន ជាបណ្តឹងមួយដ៏មានសារៈសំខាន់ចំពោះគូភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមអនុវត្តដោយបង្ខំ ឬផ្សេងទៀតមានលទ្ធភាពក្នុងការប្រើប្រាស់នូវសិទ្ធិរបស់ពួកគេម្តងទៀត ក្នុងនីតិវិធីធ្វើបណ្តឹងតវ៉ា និងផ្តល់ឱកាសដល់តុលាការក្នុងស្វែងរកយុត្តិធម៌។ យើងខ្ញុំសង្ឃឹមថាឯកសារដែលយើងខ្ញុំបានសិក្សាកន្លងមកនេះ

នឹងក្លាយទៅជាដើមទុនដ៏សំខាន់មួយសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ឱ្យយល់ពីសារៈសំខាន់នៃបណ្តឹងតវ៉ារបស់តតិយជន និងចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន។

## ២ អនុសាសន៍

ជាការសំខាន់ណាស់ ដែលអ្នកធ្វើបណ្តឹង ត្រូវដាក់ឲ្យទាន់ពេលវេលា នាពេលបានដឹងអំពីការរំលោភបំពានលើសិទ្ធិ ឬកាតព្វកិច្ចរបស់ខ្លួន។ ការចូលរួមពីយុទ្ធនាការណ៍កម្រិតថ្នាក់ជាតិដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័ន រដ្ឋ និងស្ថាប័នឯកជន ទាំងស្ថាប័នគ្រឹះស្ថានអប់រំត្រូវការជាចាំបាច់ ដើម្បីបញ្ជៀបចំណេះដឹង និងចំណេះឃើញ បានដល់ប្រជាពលរដ្ឋគ្រប់រូប ។ មិនតែប៉ុណ្ណោះ ការអប់រំពីក្នុងកម្រិតមធ្យមសិក្សា អំពីអត្ថិភាពការប្តឹងតវ៉ាក៏អាចជួយបន្ថែមទៀតដែរ ដោយសារសិស្ស និងនិស្សិតគឺជាអនាគតអ្នកជំនួញ មន្ត្រីរាជការ ជាបុគ្គលមានឥទ្ធិពលក្នុងសេចក្តីសម្រេចរបស់ក្រុមគ្រួសាររបស់ពួកគេផងដែរ ។

ទន្ទឹមនឹងនេះស្ថាប័នតុលាការ ត្រូវតែមានឯករាជភាព ដើម្បីវិនិច្ឆ័យសំណុំរឿងណាមួយប្រកដោយភាពយុត្តិធម៌។

ក្រុមហ៊ុន មេធាវី សារការី អាជ្ញាកណ្តាល ឬ មន្ត្រីរាជការគ្រប់លំដាប់ត្រូវប្រកបវិជ្ជាជីវៈ និងបំពេញតួនាទីរបស់ខ្លួនប្រកបដោយសីលធម៌ និងមនសិការខ្ពស់ ដើម្បីប្រយោជន៍ កូនក្តី អតិថិជនដែលជាប្រជាពលរដ្ឋនៅកម្ពុជា។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី២

# ឧបសម្ព័ន្ធទី៣

# ឯកសារយោង

# ឯកសារយោង

## សៀវភៅច្បាប់

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦។

## ឯកសារផ្សេងៗ

- សៀវភៅស្តីពីការពន្យល់អំពី បណ្តឹង ការតវ៉ា និងបណ្តឹងជំទាស់ ទាក់ទងនឹងការអនុវត្ត បោះពុម្ពខែវិច្ឆិកា ឆ្នាំ២០១១។
- ឯកសារសិក្ខាសាលាចំណាត់ការលើបណ្តឹងតវ៉ារបស់តតិយជន លោកមេធាវី អ៊ីវ ប៉ូលី
- ឯកសារសិក្ខាសាលាក្រោមប្រធានបទ "បណ្តឹងតវ៉ារបស់តតិយជន" ធ្វើបទបង្ហាញ ដោយលោកមេធាវី អ៊ីវ ប៉ូលី ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨។
- មេរៀនសង្ខេបនីតិរដ្ឋប្បវេណី (សាស្ត្រាចារ្យ អ៊ីវ ប៉ូលី)

## គេហទំព័រ

- https://www.bakc.org.kh/index.php/1267-maeda-yuta-jica (បានចូលមើល ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៩)
- https://www.postkhmer.com (បានចូលមើល ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩)
- https://sinchanphalkun.wordpress.com (បានចូលមើល ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៩)
- https://sinchanphalkun.wordpress.com (បានចូលមើល ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩)